វិទ្យាស្ថានគណនេយ្យករ
ជំនាញ និងសវនករកម្ពុជា
Kampuchea Institute of Certified
Public Accountants and Auditors

# ២០ របាយការណ៍ ប្រចាំឆ្នាំ ២៤

ជាសមាជិក វ.គ.ស.ក. អ្នកមានសិទ្ធិអាចស្នើ
សុំអាជ្ញាបណ្ណគណនេយ្យ និង/ ឬ សវនកម្ម។

ដើម្បីទាញយកឯកសារ

# Study online anytime anywhere

# Khmer and English available




## DOWNLOAD IT TODAY ON:

Download on the App Store

GET IT ON Google Play

(+855) 23 23 17 07 | kicpaa@kicpaa.org | www.kicpaa.org
kicpaacambodia | kicpaa | 077 241 707



allnison
ADVISORY · AUDIT · TAX SOLUTION
凱 旋 會 計 事 務 所

# EMPOWER YOUR BUSINESS in CAMBODIA

## with a Global Perspective and Expertise

ALLNISON Auditing and Consulting Co., Ltd is meant to provide unrivalled knowledge and business insights for running a business in Cambodia.

We provide one-on-one personalized and customized auditing and consulting services in full compliance with cambodian International Standard on Auditing and Cambodian International Financial Reporting Standard, and as well as tax services with respect to the regulations of Cambodia.

PrimeGlobal
Member Firm

## The Unique Industry Experience

### and International Exposure of our Professionals establish the foundation of our firm's vision.

ALLNISON's network spans the globe, having a major presence in China, Hong Kong, Malaysia, and Canada. We are committed to building long-term partnerships through integrity and responsiveness.

Our clients span a broad range of sectors, including aviation, asset and wealth management, agriculture, real estate, entertainment, hospitality, manufacturing, infrastructure, healthcare, energy, private equity, telecom, and logistics.

ALLNISON's CHINA DESK SOLUTION
With the Belt and Road Initiative driving growth, our China Desk helps clients navigate cross-border business challenges through cultural insights, regulatory understanding, and language support.

From tax planning and IPOs to compliance and translation, our experienced team delivers tailored solutions to support your global expansion.

## Our Services

- COMPANY SECRETARIAT SERVICE
- TAX FILING & ADVISORY
- AUDIT & ASSURANCE
- BOOKKEEPING & ACCOUNTING
- TRANSACTION & RESTRUCTURING
- RISK & CONTROL SOLUTIONS
- CORPORATE FINANCE
- IMMIGRATION & CONSULTING
- CUSTOMS FILING & CLEARANCE
- TRANSLATION SOLUTIONS
- ONE STOP SOLUTIONS

Licensed Audit Firm of ACAR
Audit Member Firm of KICPAA
Registered Tax Service Agent of GDT

www.allnison.com


K Professional Accountants
A member of Global Alliance PRAXITY
Audit | Accounting Outsourced | Tax | Business Advisory
K Professional Accountants is a member of PRAXITY GLOBAL ALLIANCE, a global Alliance of independent firms of accounting, audit and business advisory and an active member of Kampuchea Institute of Certified Public Accountants and Auditors (KICPAA). KPA is a licensed Audit firm from Accounting and Auditing Regulator (ACAR).
We offer local solutions at International Standards
Professional Services:
Audit and Assurance
Accounting Outsourced Solutions
Business Advisory Services
Professional Tax Services
Financial Management Training & Coaching
AI 2016's MOST INNOVATIVE ACCOUNTANCY firm
K Professional Accountants Cambodia
Our passion is to turn our practical knowledge and experiences in the industries into values which benefits our clients and stakeholders.
Darith Khun, FCCA
Managing Partner
T (office) +855 23 218 627 | T (mobile) +855 78 345 888 | E ceo@kpaglobal.com | W www.kpablobal.com
K Professional Accountants
5th Floor | CPL Building | 348 corner 205 Street | Sangkat Toul Svay Prey II, Khan Chamkarmon | Phnom Penh, Kingdom of Cambodia
Empowered by Knowledge


TOGETHER TO SOLVE YOUR BUSINESS COMPLEXITIES
ABOUT US
PAT Professional is a certified public accounting firm operated by experienced Cambodian professionals.
PAT Professional understands its clients' needs and assembles the best team to break through the clients' business complexities and financial issues. "We, together" is our slogan.
With PAT Professional, your complexity is our challenge, and your success is our success.
P A T PROFESSIONAL LIMITED
SCAN here to connect WITH US
CONTACT US
info@pat-professional.com
023 967 156/ 098 951 156
Fortune Tower #C7, 8th floor, Room# 813A, 816, 817&818, Street 182 Corner 161, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia.
PAT
One-Stop Business Solutions in Audit & Assurance, Accounting, Taxation and Corporation


BLUE Chartered Accountants and Auditors
Blue Chartered Accountants and Auditors Co, Ltd
Our Services
Audit and assurance
Bookkeeping
Tax
www.bluecaa.com info@bluecaa.com 016 669 107


A&P Accounting
ANDREW & PHILIP ACCOUNTING CO., LTD.
TAXATION
Audit
ACCOUNTING & TAXATION
INTERNAL & EXTERNAL AUDIT
BUSINESS CONSULTING SERVICES
REGISTRATION & RESEARCH
M&A & EVALUATION


TOGETHER
ME MAKE IT
HAPPEN
HLB CAMBODIA
www.hlbauditpartners.com.kh


Localize
CAMBODIA Online Accounting
& Tax Preparation Sotware
FOR BUSINESS


Technology Integration
Cloud-based solutions and automated processes that deliver efficiency, enhance accuracy, and create superior client experiences.
Comprehensive Services
Over eight years of experience in core services—accounting, tax, and business incorporation—with expanding expertise in audit, advisory, and automation.
Professional Excellence
Four Cambodian professionals holding ACCA and CPA qualifications, with specialization in compliance, audit, accounting, and advisory.
Fourmi & Partners
SUPPORTED BY KUDOS


Global scale.
Local insight.
GRANTTHORNTHON.COM.KH


AUDIT • TAX • ADVISORY
bakertilly
Services Offered by
Baker Tilly Cambodia
We offer the full range of services including:
1 Audit & Assurance
2 Taxation
3 Corporate Recovery & Restructuring
4 Internal Audit & Risk Advisory
5 Accounting
6 Corporate Secretarial & Advisory
7 Forensic
8 Global Business Solutions
9 Technology Consulting Services
10 Legal Compliance
For further information, please contact:
Baker Tilly Cambodia
info@bakertilly.com.kh
www.bakertilly.com.kh


Your
PARTNER in
Achieving Your
SUCCESS
WOORI ACCOUNTING
OUR SERVICES:
- Business Registration
- Tax Advisory and Compliance
- Accounting Services
- Audit Services
- License Acquisition
- Legal Services
For any query please contact:
+855 23 223 878
admin_01@wooriacc.com
vist our website:
www.woori accounting.com
IOC Center 6F, No. 254, Monivong Blvd., Boeung Raing, Khan Daun Penh, Phnom Penh Cambodia

# ចូលជាសមាជិក

## មូលហេតុដែលត្រូវចូលជាសមាជិក វ.គ.ស.ក.

### 1 អាជ្ញាបណ្ណ

ជាសមាជិក វ.គ.ស.ក. អ្នកអាចស្នើសុំអាជ្ញាបណ្ណគណនេយ្យ និងសវនកម្មពីនិយ័តករគណនេយ្យ និងសវនកម្ម(ន.គ.ស.)។

### 2 ទទួលស្គាល់ និង ជឿទុកចិត្ត

ទទួលស្គាល់ និងជឿទុកចិត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ និយ័តករគណនេយ្យ និងសវនកម្ម និងបង្ហាញឈ្មោះរបស់អ្នកនៅលើគេហទំព័រ វ.គ.ស.ក.។

### 3 កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD)

ជាសមាជិក វ.គ.ស.ក. ទទួលបាននូវ វគ្គបណ្តុះបណ្តាលនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងមានផ្តល់ជាវិញ្ញាបនបត្រសម្រាប់បង្កើនគុណតម្លៃវិជ្ជាជីវៈរបស់អ្នក។

### 4 បញ្ចុះតម្លៃ/ឥតគិតថ្លៃ

ទទួលបានការបញ្ចុះតម្លៃ ឬឥតគិតថ្លៃលើការចូលរួមក្នុងសិក្ខាសាលា ការបណ្តុះបណ្តាល និងព្រឹត្តិការណ៍ផ្សេងទៀតដែលរៀបចំដោយ វ.គ.ស.ក.។

### 5 បច្ចុប្បន្នភាព

បានធ្វើបច្ចុប្បន្នភាពលើបញ្ហាបច្ចុប្បន្ន ឬបញ្ហាប្រឈមដែលអាចកែលម្អអង្គភាពរបស់អ្នកសម្រាប់ពេលអនាគតឱ្យកាន់តែប្រសើរ។

### 6 ទំនាក់ទំនង

ពង្រីកបណ្តាញទំនាក់ទំនងរបស់អ្នក (network) និងពង្រឹងទំនាក់ទំនងជាមួយសមាជិក និយ័តករសំខាន់ៗ និងភាគីពាក់ព័ន្ធតាមរយៈកម្មវិធីដែលបង្កើតឡើងដោយ វ.គ.ស.ក.។

### 7 ចែករំលែក

អ្នកនឹងទទួលបានព័ត៌មានថ្មីៗអំពីការប្រែប្រួលនៃច្បាប់/បទប្បញ្ញត្តិ និងបញ្ហាបច្ចេកទេស ដែលប៉ះពាល់ដល់កាតព្វកិច្ចផ្លូវច្បាប់ ការអនុលោម និងស្តង់ដានានាតាមរយៈការចែករំលែកអត្ថបទ វីដេអូ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ វ.គ.ស.ក.ជាដើម។

### 8 ប្រយោជន៍ដល់សង្គម

អតិរេកដែលបានមកពីវិភាគទាននឹងត្រូវបានចែករំលែកសម្រាប់ជាប្រយោជន៍ដល់សង្គម និងគាំទ្រក្នុងវគ្គបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា។

**ស្កេនដើម្បីស្វែងយល់បន្ថែម**

- លក្ខខណ្ឌចូលជាសមាជិក
- ទម្រង់នៃការស្នើសុំ
- ថ្លៃសមាជិក
- គោលការណ៍កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត


**ទាក់ទងមកពួកយើង**

077 241 707 | 010 273 661 | 023 23 17 07

077 241 707

membership@kicpaa.org

### តើសមាជិក វ.គ.ស.ក.មានប៉ុន្មានប្រភេទ ?

- **សមាជិកប្រភេទក្រុមហ៊ុន**
- **សមាជិកជារូបវន្តបុគ្គល ៖**
  - សមាជិកកិត្តិយស
  - សមាជិកសកម្ម
  - សមាជិកចូលរួម
  - សមាជិកសមាគត
  - សមាជិកបម្រុង

### តើខ្ញុំគួរធ្វើដូចម្ដេចដើម្បីទទួលបានអាជ្ញាបណ្ណផ្ដល់សេវាកម្មគណនេយ្យនិង/ឬសវនកម្ម ?

អនុលោមតាម [អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្ដីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តិទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម] រូបវន្តបុគ្គល និង នីតិបុគ្គលអាចប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មបានលុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ វ.គ.ស.ក.។ បន្ទាប់មក អ្នកនឹងទទួលបានវិញ្ញាបនបត្រសមាជិកភាពដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពី ន.គ.ស.។

## ដំណើរការនៃការស្នើសុំសមាជិកភាព

### ការសាកសួរព័ត៌មាន

ទាក់ទងមកមន្ត្រីផ្នែកសមាជិកភាព ឬ ចូលទៅកាន់គេហទំព័រ (www.kicpaa.org) ដើម្បីទទួលបានព័ត៌មាន និងពាក្យស្នើសុំ

### ការដាក់ពាក្យ

បំពេញនិងដាក់ពាក្យស្នើសុំដោយភ្ជាប់ជាមួយឯកសារតម្រូវនានា មកកាន់ការិយាល័យ វ.គ.ស.ក.

### ការបង់ថ្លៃដាក់ពាក្យ

ក្នុងរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការមន្ត្រី វ.គ.ស.ក. នឹងផ្ដល់មតិយោបល់ទៅលើពាក្យស្នើសុំជូនបេក្ខជនវិញ ហើយ វ.គ.ស.ក. តម្រូវឱ្យអ្នកបង់ថ្លៃពាក្យស្នើសុំសមាជិកភាព

### ការផ្ទៀងផ្ទាត់ព័ត៌មាន

វ.គ.ស.ក. ត្រូវការរយៈពេលប្រមាណ ១ខែ ឬច្រើនជាងនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន

### ការប្រកាសលទ្ធផល

បន្ទាប់ពីការផ្ទៀងផ្ទាត់ត្រូវបានបញ្ចប់ ពាក្យស្នើសុំរបស់អ្នកនឹងត្រូវបានវាយតម្លៃដោយគណៈកម្មការចុះឈ្មោះនិងសមាជិកភាពហើយលទ្ធផលផ្លូវការនឹងត្រូវបានផ្ញើជូនអ្នកតាមរយៈអ៊ីមែល។

ជាន់ទី ៨ អាគារ វីត្រាស់ ផ្លូវ ១៦៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ កម្ពុជា

023 23 17 07

kicpaa@kicpaa.org

www.kicpaa.org



# របាយការណ៍ ប្រចាំឆ្នាំ ២០២៤

## វ. គ. ស. ក.

# មាតិកា

## របាយការណ៍ប្រចាំឆ្នាំ ២០២៤


**០១ សារពីប្រធានវិទ្យាស្ថាន និងនាយកប្រតិបត្តិ**

សារពីប្រធានវិទ្យាស្ថាន ០៣
សារពីនាយកប្រតិបត្តិ ០៥

**០២ ទិដ្ឋភាពទូទៅ វ.គ.ស.ក.**

ប្រវត្តិរបស់ វ.គ.ស.ក. ០៧
តើ វ.គ.ស.ក. ជានរណា? ០៨
សមាជិកភាព ០៨
រចនាសម្ព័ន្ធ របស់ វ.គ.ស.ក. ០៩
ក្រុមប្រឹក្សាភិបាលអាណត្តិ ១០
គណៈកម្មការ និងអនុគណៈកម្មការ ១២
លេខាធិការដ្ឋាន ១៧

**០៣ សកម្មភាពឆ្នាំ ២០២៤ វ.គ.ស.ក.**

កម្មវិធីផ្សព្វផ្សាយស្តីពីវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ១៩
កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងវគ្គបណ្តុះបណ្តាលរបស់ វ.គ.ស.ក. ៣៥
អនុស្សរណៈនៃការយោគយល់គ្នា ៤៨
កិច្ចសហការនិងការចូលរួមជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិនានា ៥០
ទស្សនកិច្ចសិក្សា ៥៨
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មការនានា និងកិច្ចប្រជុំផ្សេងៗរបស់ វ.គ.ស.ក. ៥៨
ការស្ទង់មតិ អត្ថបទ ការបោះពុម្ព និងរបាយការណ៍ប្រចាំឆ្នាំ ៦០
ការធ្វើបច្ចុប្បន្នភាព ច្បាប់ បទប្បញ្ញត្តិថ្មីៗ និងព័ត៌មានសំខាន់ៗដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈ ៦០
កម្មវិធីឧបត្ថម្ភប្រចាំឆ្នាំ២០២៤ របស់ វ.គ.ស.ក. ៦០
កម្មវិធីមហាសន្និបាតប្រចាំឆ្នាំលើកទី២១ ៦០
ការរៀបចំផែនការ គោលនយោបាយ និងបទប្បញ្ញត្តិនានា ៦១
កិច្ចសហការរៀបចំកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ៦១
កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ ៦២

**០៤ សមាជិកភាព វ.គ.ស.ក.**

សមាជិកជាប្រភេទក្រុមហ៊ុន ៦៥
សមាជិកជាប្រភេទបុគ្គល ៧១
ដំណើរការនៃការស្នើសុំសមាជិកភាព ៧២



# សារពី
# ប្រធានវិទ្យាស្ថាន និងនាយកប្រតិបត្តិ


សារពីប្រធានវិទ្យាស្ថាន ០៣

សារពីនាយកប្រតិបត្តិ ០៥



# សារពី ប្រធានវិទ្យាស្ថាន

**ជូនចំពោះ សមាជិក ដៃគូសហការ មិត្តរួមការងារ និងប្រិយមិត្ត**

ខ្ញុំបាទពិតជាមានកិត្តិយសណាស់ដែលត្រូវបានជ្រើសតាំងម្តងទៀត ជាប្រធានក្រុមប្រឹក្សាភិបាលនៃស្ថាប័នវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ក្នុងអាណត្តិទី៧ ឆ្នាំ២០២៤ ដល់ ២០២៨។ តាមរយៈការទុកចិត្តពីសមាជិក **វ.គ.ស.ក.** និងសមាជិកក្រុមប្រឹក្សាភិបាល ខ្ញុំជឿជាក់ថាយើងអាចអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនៅកម្ពុជាកាន់តែល្អប្រសើរ។

ឆ្នាំ២០២៤ ចាត់ទុកជាឆ្នាំដែលយើងសម្រេចបាននូវសមិទ្ធផលជាច្រើនតាមរយៈការអនុវត្តយុទ្ធសាស្ត្រដែលផ្តោតលើការកសាងសមត្ថភាពសមាជិក ការពង្រឹងសមត្ថភាពលេខាធិការដ្ឋាន និងការរួមចំណែកអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យឱ្យកាន់តែរឹងមាំ ដែលជំរុញឱ្យយើងអាចដាក់ពាក្យស្នើសុំជាសមាជិកពេញសិទ្ធិ ជាផ្លូវការរបស់សហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC)។ ជាការពិតយើងបានរួមគ្នាកសាង ហេដ្ឋារចនាសម្ព័ន្ធច្បាប់ ហេដ្ឋារចនាសម្ព័ន្ធវិជ្ជាជីវៈដ៏សមស្រប និងធនធានមនុស្សដែលប្រកបដោយគុណវុឌ្ឍិនិងក្រមសីលធម៌វិជ្ជាជីវៈ។ សមិទ្ធផលទាំងអស់នេះបាននឹងកំពុងក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់វិជ្ជាជីវៈគណនេយ្យបច្ចុប្បន្ន និងនាំឱ្យយើងសម្រេចបាននូវចក្ខុវិស័យប្រកបដោយមោទនភាពនិងទំនុកចិត្ត។

ជាមួយនឹងមោទនភាពនៃសមទ្ធិផលទាំងនេះ យើងតែងតែអរគុណនិងដឹងគុណចំពោះសមាជិកស្ថាបនិក អតីតប្រធាន អតីតអនុប្រធាន អតីតសមាជិកក្រុមប្រឹក្សា សមាជិក និងក្រុមការងារលេខាធិការដ្ឋាន សម្រាប់ការដឹកនាំ ការអនុវត្តយុទ្ធសាស្ត្រ ការខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត ការលះបង់ ការគាំទ្រ និងការរួមចំណែកក្នុងការធ្វើឱ្យ **វ.គ.ស.ក.** និងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា ទទួលបានលទ្ធផលដូចសព្វថ្ងៃ។

**ចក្ខុវិស័យនាពេលខាងមុខ!**

ជាមួយមហិច្ឆតារបស់ប្រទេសកម្ពុជាក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ សំណួរដ៏សាមញ្ញសម្រាប់យើងគឺថា៖ តើវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជានឹងដើរតួនាទីដូចម្តេចខ្លះ? តើយើងមានយុទ្ធសាស្ត្រដូចម្តេចដើម្បីសម្រេចបានមហិច្ឆតានេះ?

ពិតណាស់ វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម មានតួនាទីសំខាន់ក្នុងការវិនិច្ឆ័យ និងការអនុវត្ត ដើម្បីកសាងសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ និងមានស្ថិរភាពបន្ថែមទៀត ជាពិសេសនៅក្នុងយុគសម័យនៃបច្ចេកវិទ្យាឌីជីថល អស្ថិរភាពនៃសកលលោក និងការកើនឡើងនូវនិន្នាការថ្មីៗ។ យើងពិតជាអាចសម្រេចនូវគោលដៅនេះបាន តាមរយៈភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការក្នុងចំណោមវិស័យសាធារណៈ និងឯកជន វិជ្ជាជីវៈគណនេយ្យ ភ្នាក់ងារផ្តល់ជំនួយនិងការអភិវឌ្ឍ និងផ្នែកផ្សេងៗទៀតដែលនាំឱ្យយើងអាចកសាងរចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ សម្រាប់ពង្រឹងក្រមសីលធម៌ ស្តង់ដាវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តក្នុងការធ្វើសកម្មភាពប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ទស្សនវិស័យនាពេលអនាគតកាន់តែភ្លឺស្វាងជាមួយកាលានុវត្តភាពថ្មីៗ ប៉ុន្តែក៏មានបញ្ហាប្រឈមចម្បងផងដែរ ហើយដែលយើងត្រូវធ្វើការរួមគ្នាក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវច្បាប់ដ៏ជាក់លាក់ រចនាសម្ព័ន្ធវិជ្ជាជីវៈដ៏ត្រឹមត្រូវ និងធនធានមនុស្សប្រកបដោយគុណវុឌ្ឍិនិងក្រមសីលធម៌វិជ្ជាជីវៈ ដែលអាចដោះស្រាយបញ្ហាប្រឈមនាពេលអនាគតដោយជោគជ័យដែលរួមមាន បញ្ហានៃសេដ្ឋកិច្ច បច្ចេកទេស និងបច្ចេកវិទ្យា។

ខ្ញុំមានទំនុកចិត្តថា យើងនឹងទទួលបានការជួយជ្រោមជ្រែងពេញលេញពីសមាជិក និយ័តករ និងដៃគូររបស់យើង ក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងនេះឱ្យទទួលបានជោគជ័យ។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នា សម្រាប់កិច្ចគាំទ្របន្តបន្ទាប់ ហើយខ្ញុំក៏សង្ឃឹមថានឹងអាចធ្វើការជាមួយអ្នកទាំងអស់គ្នា ដើម្បីផលប្រយោជន៍វិជ្ជាជីវៈគណនេយ្យនិងសវនកម្មក្នុងប្រទេសកម្ពុជា និងអាស៊ាន។

**ឃុន ដារិទ្ធ** , CPA/FCCA
**ប្រធានក្រុមប្រឹក្សាភិបាល**



# សារពី
# នាយកប្រតិបត្តិ

**លោក លោកស្រី អ្នកនាង កញ្ញា ជាសមាជិកវិទ្យាស្ថាន ដៃគូសហការ និងមិត្តទាំងអស់**

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ជាស្ថាប័នឯករាជ្យ និងមិនរកប្រាក់ចំណេញ ដែលចូលរួមគាំទ្រ និងអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា។ យើងផ្តោតលើការបង្កើតសហគមវិជ្ជាជីវៈដ៏រឹងមាំ ប្រកបដោយក្រមសីលធម៌ និងសមត្ថភាព ដែលអាចសាងទំនុកចិត្ត និងមានវិជ្ជាជីវៈច្បាស់លាស់ជូនសារធារណជន។

នាងខ្ញុំលើកទឹកចិត្តគណនេយ្យករគ្រប់រូប ទាំងនៅវិស័យឯកជន និងសាធារណៈ ចូលរួមជាសមាជិករបស់ **វ.គ.ស.ក.** ព្រោះថា ការក្លាយជាសមាជិក **វ.គ.ស.ក.** មិនត្រឹមតែជាជំហានឆ្ពោះទៅរកការកសាងនូវអាជីពដ៏យូរអង្វែងមួយទេ ថែមទាំងបញ្ជាក់ពីការកសាងនូវសុចរិតភាព សមត្ថភាព និងគុណភាពនៃការងារផងដែរ។ ឈ្មោះសមាជិកទាំងអស់នឹងដាក់ចូលក្នុងតារាងសមាជិកភាពផ្លូវការ ដែលបង្ហោះលើគេហទំព័ររបស់ **វ.គ.ស.ក.** ហើយដែលអាចជួយឱ្យនិយោជក និងអតិថិជន អាចពិនិត្យអត្តសញ្ញាណវិជ្ជាជីវៈរបស់សមាជិក និងបង្កើនទំនុកចិត្តជាសាធារណៈចំពោះវិស័យនេះ។ សមាជិកភាពនេះក៏ផ្តល់ជាកាលានុវត្តភាពដ៏មានតម្លៃសម្រាប់ការរីកចម្រើននៃវិជ្ជាជីវៈ ការទំនាក់ទំនង និងការសិក្សាបន្ថែមជាបន្តបន្ទាប់។ ជាមួយគ្នានេះ វាក៏ជាមាគ៌ាជួយឱ្យអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបើកអាជីវកម្មគណនេយ្យ ឬសវនកម្មផ្ទាល់ខ្លួននាពេលអនាគតបានផងដែរ។

យើងនឹងបន្តការផ្តល់នូវគុណតម្លៃ ការគាំទ្រ និងអភិវឌ្ឍវិជ្ជាជីវៈដល់សមាជិកឱ្យកាន់តែរីកចម្រើននាពេលខាងមុខ។

សូមលោក លោកស្រី អ្នកនាង កញ្ញា ទទួលនូវការគោរពរាប់អានអំពីនាងខ្ញុំ

**សាឡុន ដាលី**
**នាយកប្រតិបត្តិ**



# ទិដ្ឋភាពទូទៅ វ.គ.ស.ក.


ប្រវត្តិរបស់ វ.គ.ស.ក. ០៧

តើ វ.គ.ស.ក. ជានរណា? ០៨

សមាជិកភាព ០៨

រចនាសម្ព័ន្ធ របស់ វ.គ.ស.ក. ០៩

ក្រុមប្រឹក្សាភិបាលអាណត្តិ ១០

គណៈកម្មការ និងអនុគណៈកម្មការ ១២

លេខាធិការដ្ឋាន ១៧

## ប្រវត្តិរបស់ វ.គ.ស.ក.

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(វ.គ.ស.ក.) គឺជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ និងឯករាជ្យក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ (២០០២) និងត្រូវបានជំនួសដោយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដែលបានបង្កើតក្នុងឆ្នាំ២០១៦។ វិទ្យាស្ថានត្រូវបានបង្កើតឡើង (១)ដើម្បីការពារផលប្រយោជន៍សាធារណៈនិងវិជ្ជាជីវៈ (២)គ្រប់គ្រងសមាជិករបស់ខ្លួនតាមរយៈការអភិវឌ្ឍសមត្ថភាពជំនាញ (៣)ចូលរួមជំរុញការអនុវត្តអនុលោមភាពនៃស្តង់ដា ក្រមសីលធម៌វិជ្ជាជីវៈ វិធាននិងបទប្បញ្ញត្តិនានា និង (៤)បង្កើតនិងគ្រប់គ្រងកម្មវិធីសិក្សានិងការប្រឡងគណនេយ្យករជំនាញនិងសវនករ។

## ចក្ខុវិស័យ

ជាស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតែមួយគត់ដែលមានការទទួលស្គាល់និងជឿទុកចិត្តនៅកម្ពុជា។

## បេសកកម្ម

ដើម្បីរក្សាឱ្យបាននូវប្រយោជន៍សាធារណៈតាមរយៈនិយ័តកម្ម និងការអប់រំដល់គណនេយ្យករជំនាញឱ្យស្របតាមស្តង់ដាវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ និងផ្តល់នូវទំនុកចិត្តជូនសាធារណជនប្រកបដោយវិជ្ជាជីវៈ។

## តម្លៃស្នូល

**ភាពត្រឹមត្រូវ និង យុត្តិធម៌÷** វិទ្យាស្ថានប្តេជ្ញាក្នុងការយកចិត្តទុកដាក់ចំពោះសមាជិកទាំងអស់ដោយយុត្តិធម៌ មិនលំអៀង និងស្មិតស្មេរ

**គណនេយ្យភាព÷** វិទ្យាស្ថានទទួលខុសត្រូវចំពោះ សកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន

**សុចរិតភាព÷** វិទ្យាស្ថានប្រឹងប្រែងបំពេញការងារប្រកបដោយភាពស្មោះត្រង់ ក្រមសីលធម៌ និងវិជ្ជាជីវៈ

**ការគោរព÷** វិទ្យាស្ថានធ្វើការឆ្លើយតប និងគិតគូរដោយក្តីគោរពចំពោះសមាជិកនិងសាធារណជនទាំងអស់។

**និយ័តករ**

និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)

**ស្ថាប័នវិជ្ជាជីវៈ គណនេយ្យនិងសវនកម្ម**

វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.)

## តើ វ.គ.ស.ក. ជានរណា?

ជាស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែមួយគត់នៅប្រទេសកម្ពុជា

ជាសមាជិកសមាគតរបស់ IFAC (២០០៨)

ជាសមាជិកចម្បងរបស់ AFA (២០០៣)

## សមាជិកភាព

គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ ចំនួនសមាជិក **វ.គ.ស.ក.** មានចំនួនសរុប **១៩៤០**។

**សមាជិកភាពជាប្រភេទបុគ្គល**
សរុប = ១៩១៩
ខ្មែរ = ១៣០៨
បរទេស = ៦១១

**សមាជិកសកម្មជា (សវនករ)**
- សរុប = ១៧៧
- ៩៤ ខ្មែរ
- ៨៣ បរទេស

**សមាជិកបម្រុង**
- សរុប = ៩៨៥
- ខ្មែរ ៩៨៥
- ០ បរទេស

**សមាជិកសកម្មជា (គណនេយ្យករ)**
- សរុប = ២៤
- ១៥ ខ្មែរ
- ៩ បរទេស

**សមាជិកសមាគត**
- សរុប = ២៥
- ២៣ ខ្មែរ
- ២ បរទេស

**សមាជិកចូលរួម**
- សរុប = ២០៨
- ១៩១ ខ្មែរ
- ១៧ បរទេស




## រចនាសម្ព័ន្ធ របស់ វ.គ.ស.ក.



## ក្រុមប្រឹក្សាភិបាលអាណត្តិទី៦ ២០២២-២០២៤


**ឃុន ដារិទ្ធ**
ប្រធាន


**ហុង ពិសិដ្ឋ**
អនុប្រធាន


**ឯកឧត្តម ប៊ូ ថារិន**
សមាជិក


**ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា**
សមាជិក


**ឆាយ បូរ៉ានីល**
ហេរញ្ញិក


**ហង្សស្រូផាត ម៉ូលីហ្សាណា**
សមាជិក


**ខាវ ហុង**
សមាជិក


**វឿន ប៊ុនហេង**
សមាជិក


**សុង គន្ធល**
សមាជិក


**ស៊ុន គីមហ៊ីន**
សមាជិក


**អ៊ុង គីមសុភ័ក្ត្រា**
សមាជិក


**ឡុង បូរិន្ទ**
សមាជិក


**បណ្ឌិត យាន ឫទ្ធី**
សមាជិក


**លី ប៊ុនសោម**
សមាជិក


**ឯកឧត្តម អ៊ិន មាត្រា**
សមាជិក


**លោកជំទាវ ថៃ សុខផល្លីន**
សមាជិក


**គង់ ស៊ិនរ៉ា**
សមាជិក


**ឯកឧត្តម លី ណារុឡ្យ**
សមាជិក


**សាវុធ ដាលី**
សមាជិក និងជាលេខាធិការ

## ក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ២០២៤-២០២៨


**ឃុន ដារិទ្ធ**
ប្រធាន


**នៅ វ៉េមី**
អនុប្រធាន


**ឯកឧត្តម ប៊ូ ថារិន**
សមាជិក


**ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា**
សមាជិក


**សុខ ស្រីរដ្ឋា**
ហេរញ្ញិក



**លោកជំទាវ ថៃ សុខផល្លីន**
សមាជិក



**ឯកឧត្តម លី ណាវុឌ្ឍ**
សមាជិក



**តាន់ លីនណា**
សមាជិក



**ខាវ ហុង**
សមាជិក



**ស៊ុន គីមហ៊ីន**
សមាជិក



**លី ប៊ុនសោម**
សមាជិក



**គង់ ស៊ិនរ៉ា**
សមាជិក



**ជៀម គីមហួ**
សមាជិក



**ស្រេង វុទ្ធី**
សមាជិក



**តឹក សុខវាសនា**
សមាជិក



**ហួរ វរៈបុត្ត**
សមាជិក



**ជូ សុខឡេង**
សមាជិក



**សាវុធ ដាលី**
សមាជិក និងជាលេខាធិការ

**ក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. មានមុខងារនិងភារកិច្ច ដូចខាងក្រោម÷**

- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករនិងសវនករ
- ពិនិត្យនិងអនុម័តវិធានគ្រប់គ្រងនានារបស់ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើគោលនយោបាយ និងវិធានការនានាដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ វ.គ.ស.ក.
- ពិនិត្យនិងអនុម័តលើផែនការយុទ្ធសាស្ត្រនិងគម្រោងថវិកាប្រចាំឆ្នាំដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ វ.គ.ស.ក.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការថវិកាប្រចាំឆ្នាំរបស់ វ.គ.ស.ក.
- ផ្តល់ការយល់ព្រមលើរបាយការណ៍លទ្ធផលការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ វ.គ.ស.ក.
- សម្រេចតែងតាំង ព្យួរការងារ និងបញ្ឈប់ការងាររបស់នាយកប្រតិបត្តិ និងកំណត់លាភការផ្សេងៗរបស់នាយកប្រតិបត្តិ
- សម្រេចលើគោលការណ៍ជ្រើសរើសបុគ្គលិករបស់លេខាធិការដ្ឋាននៃ វ.គ.ស.ក.
- សម្រេចលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់លេខាធិការដ្ឋាននៃ វ.គ.ស.ក.
- ពិនិត្យនិងសម្រេចលើការបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារនានា ស្របតាមតម្រូវការចាំបាច់របស់ វ.គ.ស.ក.
- រាយការណ៍ជាលាយលក្ខណ៍អក្សរអំពីផែនការ គម្រោងថវិកា និងលទ្ធផលនៃការអនុវត្តផែនការ និងថវិកាមក ក.ជ.គ. និង
- ពិនិត្យនិងសម្រេចលើសំណើបើកការិយាល័យតំណាង និង/ឬសាខាតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

# គណៈកម្មការ និងអនុគណៈកម្មការ

## គណៈកម្មការចុះឈ្មោះ និងសមាជិកភាព



**ឯកឧត្តមបណ្ឌិត ទី តាយី**
ប្រធាន



**នៅ រ៉េមី**
អនុប្រធាន



**ឯកឧត្តម ប៊ូ ថារិន**
សមាជិក



**យុន ដារិទ្ធ**
សមាជិក



**សុខ ស្រីរដ្ឋា**
សមាជិក



**ស៊ុន គីមហ៊ីន**
សមាជិក



**លី ប៊ុនសោម**
សមាជិក



**គង់ ស៊ិនរ៉ា**
សមាជិក



**ជៀម គីមហួ**
សមាជិក



**ស្រេង ឧទ្ធី**
សមាជិក



**តឹក សុខវាសនា**
សមាជិក



**ដូ សុខឡេង**
សមាជិក



**ខាវ ហុង**
សមាជិក



**សាឌុធ ដាលី**
សមាជិក



**គីង កែវពិសី**
លេខាធិការ

**គណៈកម្មការចុះឈ្មោះនិងសមាជិកភាពមានភារកិច្ចដូចខាងក្រោម÷**

- ពិនិត្យនិងសម្រេចលើលក្ខខណ្ឌតម្រូវនិងគុណវុឌ្ឍិសម្រាប់ចូលជាសមាជិករបស់ វ.គ.ស.ក.
- ពិនិត្យនិងសម្រេចផ្តល់សមាជិកភាពដល់រូបវន្តបុគ្គល និង/ឬ នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងសម្រេចលើការព្យួរ និងការដកហូតសមាជិកភាពនៃសមាជិករបស់ វ.គ.ស.ក.
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិករបស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

# គណៈកម្មការបច្ចេកទេស



**នៅ រ៉េមី**
ប្រធាន



**ខាវ ហុង**
អនុប្រធាន



**ឃុន ដារិទ្ធ**
សមាជិក



**សុខ ស្រីរដ្ឋា**
សមាជិក



**ស៊ុន គីមហ៊ីន**
សមាជិក



**គង់ ស៊ិនរ៉ា**
សមាជិក



**ជៀម គីមហួ**
សមាជិក



**ស្រេង ឧុទ្ធី**
សមាជិក



**ជុំ សុខឡេង**
សមាជិក



**សាឧុធ ដាលី**
សមាជិក



**តំណាងលេខាធិការដ្ឋាន**
លេខាធិការ

**គណៈកម្មការបច្ចេកទេសមានភារកិច្ចដូចខាងក្រោម÷**

- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលរៀបចំដោយក្រុមប្រឹក្សាជាតិគណនេយ្យ (បច្ចុប្បន្នជា និយ័តករគណនេយ្យនិងសវនកម្ម)
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាងដែលបានចេញផ្សាយ ដោយក្រុមប្រឹក្សាជាតិគណនេយ្យ (បច្ចុប្បន្នជា និយ័តករគណនេយ្យនិងសវនកម្ម) ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ សហព័ន្ធគណនេយ្យករអន្តរជាតិ និងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗទៀត
- ផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសពាក់ពន្ធ័នឹងគណនេយ្យ សវនកម្មនិងការអះអាង ពន្ធដារ ក្រមសីលធម៌ អភិបាលកិច្ច និងការងារពាក់ព័ន្ធផ្សេងទៀត
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

# គណៈកម្មការអប់រំ និងបណ្ដុះបណ្ដាល



**ស៊ុន គីមហ៊ីន**
ប្រធាន



**ស្រេង ទុទ្ធី**
អនុប្រធាន



**ឯកឧត្តម ប៊ូ ថារិន**
សមាជិក



**ឃុន ដារិទ្ធ**
សមាជិក



**នៅ អ៊ើមី**
សមាជិក



**លោកជំទាវ ថៃ សុខផល្លីន**
សមាជិក



**ឯកឧត្តម លី ណារុឡា**
សមាជិក



**ជៀម គីមហួ**
សមាជិក



**ហួរ ទរៈបុត្ត**
សមាជិក



**ដូ សុខឡេង**
សមាជិក



**តឹក សុខវាសនា**
សមាជិក



**សាវុធ ដាលី**
សមាជិក



**ជា ធួន**
លេខាធិការ

**គណៈកម្មការអប់រំនិងបណ្ដុះបណ្ដាលមានភារកិច្ចដូចខាងក្រោម÷**

- រៀបចំនិងអនុវត្តតាមផែនការយុទ្ធសាស្ត្រនិងទិសដៅការងារដែលបានដាក់ចេញដោយគណៈកម្មាធិការជាតិគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- រៀបចំ អភិវឌ្ឍ និងគ្រប់គ្រងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀតស្របតាមតម្រូវការនិងការអភិវឌ្ឍនៃវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា
- រៀបចំ និងគ្រប់គ្រងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀតរបស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងៗដែល ក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

# គណៈកម្មការស៊ើបអង្កេតនិងវិន័យ



**គង់ ស៊ិនរ៉ា**
ប្រធាន



**ស្រេង ឧុទ្ធី**
អនុប្រធាន



**ឃុន ដារិទ្ធ**
សមាជិក



**ឯកឧត្តម ប៊ូ ថារិន**
សមាជិក



**នៅ វ៉េមី**
សមាជិក



**តឹក សុខវាសនា**
សមាជិក



**តំណាងលេខាធិការដ្ឋាន**
លេខាធិការ

**គណៈកម្មការស៊ើបអង្កេតនិងវិន័យមានភារកិច្ចដូចខាងក្រោម÷**

- ទទួលនិងដោះស្រាយបណ្តឹងពីតតិយជនពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន
- បណ្តឹងឬវិវាទរវាងសមាជិកផងគ្នា
- ការមិនគោរពតាមក្រមសីលធម៌របស់សមាជិក
- ពិនិត្យ វាយតម្លៃនិងដាក់ពិន័យលើសមាជិកដែលបានប្រព្រឹត្តខុស និង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក. ប្រគល់ជូន។

## អនុគណៈកម្មការស៊ើបអង្កេត



**ជៀម គីមហួ**
ប្រធាន



**ជួ សុខឡេង**
អនុប្រធាន



**ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា**
សមាជិក



**លោកជំទាវ ថៃ សុខផល្លីន**
សមាជិក



**យុន ដារិទ្ធ**
សមាជិក



**នៅ រ៉េមី**
សមាជិក



**សារុធ ដាលី**
សមាជិក



**តំណាងលេខាធិការដ្ឋាន**
លេខាធិការ

## អនុគណៈកម្មការវិន័យ



**សុង ស្រីរដ្ឋា**
ប្រធាន



**ខាវ ហុង**
អនុប្រធាន



**លី ប៊ុនសោម**
សមាជិក



**តាន់ លីនណា**
សមាជិក



**ហួរ វរៈបុត្ត**
សមាជិក



**តំណាងលេខាធិការដ្ឋាន**
លេខាធិការ

# លេខាធិការដ្ឋាន



**សាវុធ ដាលី**
នាយកប្រតិបត្តិ



**ជា ឆួន**
នាយកផ្នែកអប់រំ



**គីម ព្រែក**
អ្នកគ្រប់គ្រងផ្នែក
ព័ត៌មានវិទ្យា



**គីង កែវពិសី**
មន្ត្រីជាន់ខ្ពស់ផ្នែកចុះឈ្មោះ
និងសមាជិកភាព



**ប៊ុច សុវណ្ណរតនៈ**
មន្ត្រីផ្នែកសមាជិកភាព



**វណ្ណ សុធារ៉ា**
មន្ត្រីផ្នែករដ្ឋបាល និង
គ្រប់គ្រងកម្មវិធី



**នឿន ចាន់វាសនា**
មន្ត្រីផ្នែកអប់រំ



**ទឹក រ៉ា**
ជំនួយការផ្នែកអប់រំ



**ស្រ៊ុន សីហឫទ្ធិ**
ជំនួយការផ្នែករដ្ឋបាល



**សោម សុវណ្ណនីតា**
ជំនួយការផ្នែកសមាជិកភាព



**រ័ត្ន សុខលក្ខិណា**
ជំនួយការផ្នែកសមាជិកភាព

**លេខាធិការដ្ឋាននៃ វ.គ.ស.ក. មានមុខងារនិងភារកិច្ចដូចខាងក្រោម÷**

- រៀបចំគ្រប់គ្រង និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ វ.គ.ស.ក.
- រៀបចំកិច្ចប្រជុំរបស់ វ.គ.ស.ក.
- រៀបចំនិងអនុវត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គម្រោងថវិកាប្រចាំឆ្នាំ និងផែនការនានា របស់ វ.គ.ស.ក.
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងវិធាននានាសម្រាប់ការគ្រប់គ្រង វ.គ.ស.ក.
- លើកសំណើសុំបើកការិយាល័យនៅតាម បណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- សហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានឧត្តមសិក្សាជាតិ និងអន្តរជាតិដើម្បីជំរុញ ការអនុវត្តកម្មវិធីសិក្សាគណនេយ្យស្រប តាមបទដ្ឋានអន្តរជាតិ
- ធ្វើជាតំណាង វ.គ.ស.ក. ក្នុងទំនាក់ទំនងជាមួយតតិយជន ដូចជា ស្ថាប័ននិយ័តករជាតិ ស្ថាប័នវិជ្ជាជីវៈគណនេយ្យក្នុងតំបន់ និងអន្តរជាតិដើម្បីលើកកម្ពស់ និងការពារវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា
- រាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីលទ្ធផលនៃការអនុវត្តផែនការ និងថវិកាប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលរបស់ វ.គ.ស.ក.
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាល នៃ វ.គ.ស.ក. ប្រគល់ជូន។



# សកម្មភាពឆ្នាំ ២០២៤ វ. គ. ស. ក.


- កម្មវិធីផ្សព្វផ្សាយស្តីពីវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ១៩
- កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងវគ្គបណ្តុះបណ្តាលរបស់ វ. គ. ស. ក. ៣៥
- អនុស្សរណៈនៃការយោគយល់គ្នា ៤៨
- កិច្ចសហការនិងការចូលរួមជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិនានា ៥០
- ទស្សនកិច្ចសិក្សា ៥៨
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មការនានា និងកិច្ចប្រជុំផ្សេងៗរបស់ វ. គ. ស. ក. ៥៨
- ការស្ទង់មតិ អត្ថបទ ការបោះពុម្ព និងរបាយការណ៍ប្រចាំឆ្នាំ ៦០
- ការធ្វើបច្ចុប្បន្នភាព ច្បាប់ បទប្បញ្ញត្តិថ្មីៗ និងព័ត៌មានសំខាន់ៗដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈ ៦០
- កម្មវិធីឧបត្ថម្ភប្រចាំឆ្នាំ២០២៤ របស់ វ. គ. ស. ក. ៦០
- កម្មវិធីមហាសន្និបាតប្រចាំឆ្នាំលើកទី២១ ៦០
- ការរៀបចំផែនការ គោលនយោបាយ និងបទប្បញ្ញត្តិនានា ៦១
- កិច្ចសហការរៀបចំកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ៦១
- កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ ៦២

## កម្មវិធីផ្សព្វផ្សាយស្តីពីវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

សិក្ខាសាលាផ្សព្វផ្សាយ
“ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នាល្ងាចថ្ងៃពុធ ៧ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិស្តីទី នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យនិងនិស្សិតនៃសាខាសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យនិងនិស្សិត ប្រមាណ៨០រូបនៅសាលប្រជុំនៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ខេត្តព្រះសីហនុ។

កិច្ចប្រជុំលើសេចក្តីព្រាងប្រកាសស្តីពី
“ការបង្ហាញព័ត៌មានចីរភាព”



នាព្រឹកថ្ងៃសុក្រ ៩ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិស្តីទី នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងប្រកាសស្តីពី “**ការបង្ហាញព័ត៌មានចីរភាព**” សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម សៀង ធីរិទ្ធ** អគ្គនាយករងនៃនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ**ន.ម.ក.**។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងក្នុងគោលបំណងពិភាក្សានិងផ្តល់នូវធាតុចូលបន្ថែមដើម្បីឱ្យសេចក្តីព្រាងប្រកាសនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ កិច្ចប្រជុំនេះមានការចូលរួមពីតំណាងក្រុមហ៊ុនផ្សារមូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រដែលជាអ្នកអនុវត្តផ្ទាល់ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រជាច្រើនរូបនៅបន្ទប់ប្រជុំជាន់ទី៣ នៃទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបានបញ្ចប់នៅវេលាម៉ោង១២និង០០នាទីថ្ងៃត្រង់ ប្រកបដោយផ្លែផ្កា និងសហប្រតិបត្តិការខ្ពស់។

សិក្ខាសាលាផ្សព្វផ្សាយ
“ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នាព្រឹកថ្ងៃពុធ ១៤ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិស្តីទី នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យនិងនិស្សិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្រោមអធិបតីភាព លោក **សេង តុលា** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យនិងនិស្សិតប្រមាណជាង១៤០រូបនៅសាលប្រជុំនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

## សិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នាព្រឹក ថ្ងៃសុក្រ ៨ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ លោកស្រី **សាទុធ ដាលី** នាយកប្រតិបត្តិស្តីទី នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យនិងនិស្សិតប្រមាណ២០០រូបនៅសាលប្រជុំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

---

## កម្មវិធី “ពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៣-២០២៤ និងប្រគល់ប័ណ្ណសរសើរដល់និស្សិតឆ្នើម”



នារសៀលថ្ងៃអាទិត្យ ៩កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ លោក **ជា ឆួន** នាយកផ្នែកអប់រំ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា តំណាងលោកស្រី **សាទុធ ដាលី** នាយកប្រតិបត្តិស្តីទីនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស និងផ្តល់ជាបទបង្ហាញលើការវិវត្តន៍នៃវិស័យគណនេយ្យ និងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ក្នុងកម្មវិធី “**ពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៣-២០២៤ និងប្រគល់ប័ណ្ណសរសើរដល់និស្សិតឆ្នើម**” នៃវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងស្វាគមន៍និស្សិតឆ្នាំ២០២៣-២០២៤ ក៏ដូចជាអបអរសាទរដល់និស្សិតឆ្នើមប្រចាំវិទ្យាស្ថានផងដែរ។ កម្មវិធីមានការចូលរួមពីសាស្ត្រាចារ្យនិងនិស្សិតប្រមាណ៤០០រូប ដែលបានរៀបចំឡើងនៅអាគារ CJCC សាលអង្គរគីហ្សូណានិងបានបញ្ចប់នៅវេលាម៉ោង៥និង៤០នាទីល្ងាចនាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កានិងភាពរីករាយក្រៃលែង។

---

## សិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នាល្ងាចថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ លោកស្រី **សាទុធ ដាលី** នាយកប្រតិបត្តិស្តីទីនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យ និងនិស្សិត ប្រមាណសរុប ១៨០រូបនៅសាលប្រជុំនៃសាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប។

## កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី “សេចក្តីព្រាងអនុក្រឹត្យ ស្តីពី ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម”



នាព្រឹកថ្ងៃចន្ទ ៩ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា អមដោយលោកស្រី **សាខុធ ដាលី** នាយកប្រតិបត្តិស្តីទីនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី “**សេចក្តីព្រាងអនុក្រឹត្យ ស្តីពី ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម**” ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ទី តាយី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ គោលបំណងនៃកិច្ចប្រកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះ គឺដើម្បីទទួលបាននូវធាតុចូល អនុសាសន៍ ក៏ដូចជាសំណូមពរនានា ដែលរួម ចំណែកស្ថាបនាសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តមួយនេះឱ្យកាន់តែល្អប្រសើរ។ កិច្ចប្រជុំពិគ្រោះយោបល់នេះ មានការចូលរួមពីតំណាងក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធជាច្រើនរូបនៅសណ្ឋាគារភ្នំពេញ។

---

## កិច្ចប្រជុំពិគ្រោះយោបល់លើ “សេចក្តីព្រាងប្រកាសពីការដាក់កម្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ”



នាព្រឹក ថ្ងៃចន្ទ ១ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា អមដោយលោកស្រី **សាខុធ ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើ “**សេចក្តីព្រាងប្រកាសពីការដាក់កម្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ**” ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ទី តាយី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អមដោយ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងអគ្គនាយករងនៃ**ន.គ.ស.**។ គោលបំណងនៃកិច្ចប្រជុំពិគ្រោះយោបល់នេះ គឺធ្វើឡើងដើម្បីទទួលបាននូវធាតុចូល អនុសាសន៍ ក៏ដូចជាសំណូមពរនានា ដែលរួមចំណែកស្ថាបនាសេចក្តីព្រាងប្រកាសមួយនេះឱ្យកាន់តែល្អប្រសើរ។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះ មានការចូលរួមពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណនេយ្យករនិងសវនករអង្គភាពមិនស្វែងរកប្រាក់ចំណេញ តំណាងក្រសួង ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ សរុបប្រមាណ១០០រូប នៅសណ្ឋាគារភ្នំពេញ។

---

## ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ



នាព្រឹកថ្ងៃចន្ទ ១៥ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា បាននិមន្តព្រះសង្ឃសូត្រមន្តចំរើនព្រះបរិត្ត សុំសេចក្តីសុខ សិរីសួស្តី ក្នុងឱកាសពីធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលនឹងឈានមកដល់នាពេលខាងមុខនេះ។ បន្ទាប់ពីពិធីសូត្រមន្ត ចំរើនព្រះបរិត្ត លោកស្រី **សាខុធ ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និងក្រុមការងារនៃលេខាធិការដ្ឋាន **វ.គ.ស.ក.** ទាំងអស់បានប្រគេនទេយ្យវត្ថុ និងបច្ច័យដល់ព្រះសង្ឃចំនួន២អង្គ ទៅតាមគន្លងប្រពៃណីព្រះពុទ្ធសាសនា។ ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្ងៃថ្លានេះផងដែរ លោកស្រី **សាខុធ ដាលី** និងក្រុមការងារនៃលេខាធិការដ្ឋាន ទាំងអស់បានបួងសួងដល់ទេវតាឆ្នាំថ្មី ឆ្នាំរោង ព្រះនាម មហោទរាទេវី បុត្រីទី៧ របស់កបិលមហាព្រហ្ម សូមជួយតាមថែរក្សាការពារ និងសូមពរជ័យសិរីមង្គលក្នុងការប្រកបការងារឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យសមាជិក **វ.គ.ស.ក.** ទាំងអស់ឱ្យជួបតែពុទ្ធពរ ទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ប្រកាសស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ"



នាព្រឹកថ្ងៃចន្ទ ៦ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា អមដោយលោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "**ប្រកាសស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ**" ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្ដម ម៉ិ ដារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ គោលបំណងនៃកម្មវិធីសិក្ខាសាលានេះ គឺធ្វើឡើងដើម្បីបញ្ជ្រាបការយល់ដឹងកាន់តែច្បាស់អំពី បែបបទ នីតិវិធី ការស្នើសុំអាជ្ញាបណ្ណ និងសិទ្ធិ កាតព្វកិច្ចរបស់ម្ចាស់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយនេះ មានការចូលរួមពីតំណាងនៃអង្គភាពក្រោមឱវាទ **អ.ស.ហ.** អគ្គនាយកដ្ឋានពន្ធដារ ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ស្ថាប័នឯកជន រួមទាំងសាធារណជនសរុបប្រមាណ១៧០រូប នៅសណ្ឋាគារភ្នំពេញ។

---

កិច្ចប្រជុំជាមួយ កញ្ញា Tanya Musumhi តំណាងសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC)



នារសៀលថ្ងៃចន្ទ ៦ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង លោកស្រី **នាន មុនី** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្ដម ម៉ិ ដារិន** អគ្គនាយកនៃ **ន.គ.ស.** បានបើកកិច្ចប្រជុំជាមួយ កញ្ញា Tanya Musumhi តំណាងសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) និងដោយមានការអញ្ជើញចូលរួមពី លោក **ហុង ពិសិដ្ឋ** អនុប្រធានក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** លោក **អ៊ឹង គឹមសុតាំភ្លា** ប្រធានគណៈកម្មការបច្ចេកទេសនិងជាសមាជិកក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិ **វ.គ.ស.ក.** និងមន្ត្រីជំនាញនៃ **ន.គ.ស.** ដើម្បីពិភាក្សាទៅលើ÷

១. ការធ្វើបច្ចុប្បន្នភាព និងលក្ខខណ្ឌលម្អិតរបស់ **វ.គ.ស.ក.** ក្នុងការស្នើសុំជាសមាជិកពេញសិទ្ធរបស់ IFAC និង

២. កិច្ចសហប្រតិបត្តិការរួមគ្នានាពេលខាងមុខ។

កិច្ចប្រជុំពិភាក្សាបានរៀបចំឡើងដោយ **វ.គ.ស.ក.** នៅបន្ទប់ប្រជុំ និងបានបញ្ចប់នូវវេលាម៉ោង ៥និង១៥នាទីល្ងាច នាថ្ងៃ ខែ ឆ្នាំដដែលប្រកបដោយផ្លែផ្កា និងកិច្ចសហប្រតិបត្តិការខ្ពស់។

## កម្មវិធីប្រជុំពិគ្រោះយោបល់ស្តីពី “ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញ (ISA for LCEs)”



នាព្រឹកថ្ងៃសុក្រ ៣ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ លោកស្រី **សាទុន ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានអញ្ជើញចូលរួមកម្មវិធីប្រជុំពិគ្រោះយោបល់ស្តីពី “**ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញ** (ISA for LCEs)” ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។

គោលបំណងនៃកិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងដើម្បីប្រមូលធាតុចូលជាមូលដ្ឋានសម្រាប់ពិចារណាក្នុងការរៀបចំសេចក្តីព្រាងប្រកាសដាក់ឱ្យអនុវត្តស្តង់ដា ISA For LCEs។

កម្មវិធីប្រជុំពិគ្រោះយោបល់នេះ មានការចូលរួមពីតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ស្ថាប័នជាតិនិងអន្តរជាតិ រួមទាំងសាធារណជន សរុប៦៥នាក់ នៅអាគារ ៣៤៥។

---

## ការផ្សព្វផ្សាយ អំពីសមាជិកភាព និងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ដល់បុគ្គលិករបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា



នាព្រឹកថ្ងៃសុក្រ ៣ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានចូលរួមផ្សព្វផ្សាយ អំពីសមាជិកភាព និងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ដល់បុគ្គលិករបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា និងអ្នកចូលរួមផ្សេងៗទៀត ក្នុងកម្មវិធីដែលបានរៀបចំឡើងដោយក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា ស្តីពី “Learning and Development Day” ចាប់ពីម៉ោង៩និង០០នាទីព្រឹក នៅការិយាល័យក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា។ កម្មវិធីនេះមាន ការជជែក និងពន្យល់ពីក្រុមការងារ **វ.គ.ស.ក.** និងការចូលរួមឆ្លើយសំណួរយករង្វាន់យ៉ាងសប្បាយរីករាយ។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងដើម្បី÷

១. ផ្សព្វផ្សាយដល់បុគ្គលិកក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា និងអ្នកចូលរួមសិក្សាស្វែងយល់កាន់តែច្បាស់ពី **វ.គ.ស.ក.**

២. ពន្យល់ពីការចូលជាសមាជិករបស់ **វ.គ.ស.ក.** និង

៣. ផ្សព្វផ្សាយអំពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ដល់បុគ្គលិកក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា ដែលកំពុងបម្រើការងារផ្នែកគណនេយ្យបានសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ផងដែរ។

កម្មវិធីនេះបានបញ្ចប់នៅវេលាម៉ោង១០និង ០០នាទីព្រឹកប្រកបដោយភាពសប្បាយរីករាយ និងភាពស្និទ្ធស្នាលក្រៃលែង។

---

## កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើ សេចក្តីព្រាងប្រកាសស្តីពី “ការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង”



នាព្រឹកថ្ងៃចន្ទ ១៣ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** និងលោក **ហុង ពិសិដ្ឋ** អនុប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើ សេចក្តីព្រាងប្រកាសស្តីពី “**ការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង**” ក្រោមអធិបតីភាពលោក **ជេង ដាត** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម។

គោលបំណងនៃកិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងដើម្បីទទួលបាននូវធាតុចូល អនុសាសន៍ឬសំណូមពរនានាដើម្បីស្ថាបនាសេចក្តីព្រាងនេះឱ្យកាន់តែល្អប្រសើរ។

កម្មវិធីប្រជុំពិគ្រោះយោបល់នេះ មានការចូលរួមពីតំណាងក្រុមហ៊ុនគណនេយ្យនិងសវនមកម្ម ស្ថាប័នជាតិនិងអន្តរជាតិ រួមទាំងសាធារណជន សរុប៩២នាក់ នៅអាគារ ៣៤៥។

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន AFA



នាថ្ងៃព្រហស្បតិ៍ ៧ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ លោក **យុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** រួមជាមួយលោក **ឌេន ផាត** អគ្គនាយករងនៃ **ន.គ.ស.** អមដំណើរដោយលោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** និងលោក **អ៊ិន បុត្រា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃ **ន.គ.ស.** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន AFA (ASEAN Federation of Accountants) លើកទី១៣៨ នៅសណ្ឋាគារ Mandarin Oriental នាប្រទេសម៉ាឡេស៊ី។ កិច្ចប្រជុំនេះក៏មានការចូលរួមពី និងថ្នាក់ដឹកនាំ និងតំណាងស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្មក្នុងតំបន់អាស៊ានជាច្រើនរូប។

កិច្ចប្រជុំនេះបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃវិស័យគណនេយ្យនិងសវនកម្ម និងការពង្រឹងកិច្ចសហប្រតិបត្តិការនៃស្ថាប័នវិជ្ជាជីវៈក្នុងតំបន់ផងដែរ។ បន្ថែមពីលើនេះ កិច្ចប្រជុំក៏បានផ្តល់ជាធាតុចូលសំខាន់ៗ និងទិសដៅជាច្រើនសម្រាប់ AFA ក៏ដូចជា **វ.គ.ស.ក.** ក្នុងការកសាងនូវយុទ្ធសាស្ត្ររបស់ខ្លួនឱ្យស្របតាមយុទ្ធសាស្ត្រតំបន់ និងពិភពលោក។ កិច្ចប្រជុំបានបញ្ចប់ដោយភាពស្និទ្ធស្នាល និងរីករាយយ៉ាងក្រៃលែង។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នាព្រឹកថ្ងៃអង្គារ ៤ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានអញ្ជើញចូលរួម និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

-ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ

-ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ

-ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យ និងនិស្សិត សរុប ២០០រូបនៅសាលប្រជុំនៃសាខាសាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## មហាសន្និបាតប្រចាំឆ្នាំលើកទី២១



នៅរសៀល ថ្ងៃសុក្រ ១៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានប្រារព្ធមហាសន្និបាតប្រចាំឆ្នាំលើកទី ២១ របស់ខ្លួន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។ មហាសន្និបាតប្រចាំឆ្នាំនេះត្រូវបានធ្វើឡើងដើម្បីរាយការណ៍ជូនសមាជិករបស់ **វ.គ.ស.ក.** នូវសកម្មភាព ក៏ដូចជាសមិទ្ធផលដែល **វ.គ.ស.ក.** បានអនុវត្ត និងសម្រេចបានក្នុងឆ្នាំ២០២៣កន្លងមក សេចក្តីរាយការណ៍ស្តីពីរបាយការណ៍ហិរញ្ញវត្ថុ

ការជ្រើសរើសសវនករឯករាជ្យសម្រាប់ឆ្នាំ២០២៤របស់ **វ.គ.ស.ក.** ការយល់ស្របទៅលើរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឆ្នាំ២០២៣ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** អាណត្តិទី៧ (២០២៤-២០២៨) និងបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាល។

ជាកិច្ចចាប់ផ្តើម លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.**នៃអាណត្តិទី៦ (២០២២-២០២៤) បានបង្ហាញពីមោទនភាពដែលសមាជិក **វ.គ.ស.ក.** នាពេលបច្ចុប្បន្នមានចំនួនច្រើននិងប្រកបដោយគុណវុឌ្ឍិ សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ដែលនេះគឺជាគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រការរីកចម្រើននៃសេដ្ឋកិច្ចជាតិរបស់កម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ លោកប្រធាន ក៏បានលើកឡើងអំពី ការអនុវត្តផែនការយុទ្ធសាស្ត្រ **វ.គ.ស.ក.** ដែលផ្តោតលើសសរស្តម្ភចំនួន៣÷

(១) ការអភិវឌ្ឍសមាជិកតាមរយៈការបង្កើនចំនួនសមាជិក និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD)

(២) ធានានិរន្តរភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់ **វ.គ.ស.ក.**

(៣) ការចូលរួមអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មជាមួយរាជរដ្ឋាភិបាលដែលមាន **ន.គ.ស.** ជាសេនាធិការ ។

លោកប្រធានក៏បានសំណូមពរសមាជិកចូលរួមអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មឱ្យកាន់តែមានការរីកចម្រើននិងបានគោរពថ្លែងអំណរគុណ **ឯកឧត្តមបណ្ឌិត ចី តាឃី** ដែលជាស្ថាបនិកវិស័យគណនេយ្យនិងសវនកម្ម **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម និងថ្នាក់ដឹកនាំ **ន.គ.ស.** ដែលតែងតែគាំទ្រ **វ.គ.ស.ក.**។

ជាកិច្ចបន្ទាប់ **ឯកឧត្តម ម៉ី ថារិន** បានសម្តែងក្តីសោមនស្សរីករាយដោយបានចូលរួមមហាសន្និបាតលើកទី២១ របស់ **វ.គ.ស.ក.**។ ក្នុងនាម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និងនិយ័តករគណនេយ្យនិងសវនកម្ម ឯកឧត្តម សូមវាយតម្លៃខ្ពស់ និងកោតសរសើរដល់ការប្រឹងប្រែង និងលះបង់របស់ក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** អាណត្តិទី៦ និងអាណត្តិមុនៗ ក្នុងការចូលរួមអភិវឌ្ឍវិជ្ជាជីវៈនៅកម្ពុជាអស់ពីកម្លាំងកាយចិត្ត និងប្រកបដោយមនសិការវិជ្ជាជីវៈយ៉ាងពិតប្រាកដ។ ឯកឧត្តមបានលើកឡើងបន្ថែមថា សម្រាប់អាណត្តិទី៧ (២០២៤-២០២៨)ថ្មីនេះ មានបេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** ច្រើនលើសអាណត្តិមុនៗ ដែលនេះជាការបង្ហាញឱ្យឃើញពី ឆន្ទៈមោះមុតរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាអ្នកវិជ្ជាជីវៈ ក្នុងការចូលរួមចំណែកអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ។ ឯកឧត្តម បានលើកបន្ថែមថា និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង **វ.គ.ស.ក.** ជាស្ថាប័នចូលរួមទទួលខុសត្រូវបាននឹងកំពុងយកចិត្តទុកដាក់ប្រកបដោយស្មារតីសកម្ម និងបុរេសកម្ម ក្នុងការអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា។ វត្តមាននៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ គឺជាមូលដ្ឋានគ្រឹះតែមួយគត់ សម្រាប់ស្ថាប័នពាក់ព័ន្ធ ពិសេសនិយ័តករគណនេយ្យនិងសវនកម្ម និង **វ.គ.ស.ក.** ដើម្បីរៀបចំយុទ្ធសាស្ត្រនិងផែនការ សកម្មភាពរបស់ខ្លួន ក្នុងបេសកកម្មអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា។ រហូតមកដល់ពេលនេះ ក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ កំពុងតែត្រូវបានយកមកពិចារណាក្នុងការកែសម្រួល ដើម្បីបំពេញនូវការខ្វះចន្លោះ និងសម្របតាមការវិវត្តនៃវិស័យនិងវិជ្ជាជីវៈនេះនៅក្នុងពិភពលោក និងតំបន់។ ដូចគ្នានេះដែរ សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា រយៈពេល១០ឆ្នាំ (២០២១-២០៣០) ត្រូវបានរៀបចំរួចរាល់ និងរង់ចាំតែការអនុម័តដាក់ឱ្យអនុវត្តដោយ ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាពេលដ៏ខ្លីខាងមុខ។ ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ គឺមានសសរស្តម្ភចំនួន ៦ ដែលទាមទារឱ្យស្ថាប័នដែលនឹងចូលរួមទទួលខុសត្រូវអនុវត្ត គឺមាន **ន.គ.ស.** និង **វ.គ.ស.ក.**។ ក្នុងន័យនេះ ស្ថាប័នទាំងពីរត្រូវប្រកាន់យកអភិក្រមការងារ គឺ រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ។ ម្យ៉ាងទៀត ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ ស្ថាប័នទាំងពីរ ត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដោយផ្តើមចេញពី អភិបាលកិច្ចល្អនៃស្ថាប័ន ការពង្រឹងភាពជាអ្នកដឹកនាំនៃអ្នកគ្រប់គ្រង ភាពគ្រប់គ្រាន់នៃវិធានគ្រប់គ្រងផ្ទៃក្នុង និងសមត្ថភាពខ្ពស់ របស់មន្ត្រី និងបុគ្គលិក ។ ឯកឧត្តមក៏បានលើកនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលនៃរដ្ឋសភាអាណត្តិទី ៧ ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់បាវចនា៥ គឺ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់យកជាមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០២៥ ដែលក្នុងនោះ មូលដ្ឋានគ្រឹះទី១ គឺការអភិវឌ្ឍមូលធនមនុស្ស។ គណនេយ្យករជំនាញនិងសវនករគឺជាមូលធនមនុស្សមួយផ្នែកដែលមិនអាចខ្វះបាន នៅក្នុងការការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ឯកឧត្តម ក៏បានស្នើដល់ សមាជិក សមាជិកា គ្រប់ប្រភេទ ពិសេសគណៈគ្រប់គ្រងអាណត្តិថ្មីរបស់ **វ.គ.ស.ក.** ដូចជា÷

១. បន្តចូលរួមយ៉ាងសកម្ម និងបុរេសកម្ម នៅក្នុងរាល់សកម្មភាពទាំងអស់របស់និយ័តករគណនេយ្យនិងសវនកម្ម របស់ **វ.គ.ស.ក.** និងរបស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុនៃការអភិវឌ្ឍ និងលើកកម្ពស់វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា

២. បន្តសាមគ្គីគ្នា ក្រោមបរិយាកាសយោគយល់ និងអត់ឱនគ្នាជាអតិបរមា ក្នុងការបំពេញតួនាទី ភារកិច្ច ទាំងនៅក្នុងក្របខណ្ឌនៃការគ្រប់គ្រងស្ថាប័ន និងទាំងនៅក្នុងការប្រតិបត្តិវិជ្ជាជីវៈ ព្រមទាំងជៀសឱ្យបានដាច់ខាតពីអរិភាពនៃវិជ្ជាជីវៈ (Professional Hostility)

៣. **វ.គ.ស.ក.** បន្តយកចិត្តទុកដាក់បន្ថែមលើការកៀងគរសមាជិករបស់ខ្លួន ឱ្យបានកាន់តែច្រើន ដោយរក្សានូវគុណភាព និងគុណតម្លៃវិជ្ជាជីវៈ

៤. សមាជិក សមាជិកា បន្តចូលរួម និងណែនាំអតិថិជនរបស់ខ្លួន ពង្រឹងការអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួននិងមានប្រសិទ្ធភាព ពិសេសការគ្រប់គ្រងសមាជិកភាព ធានាបាននូវការគោរពច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ បទប្បញ្ញត្តិ វិធាន និងគោលនយោបាយនានារបស់ **វ.គ.ស.ក.**

៥. **វ.គ.ស.ក.** បន្តជំរុញការរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត (CPD) ឱ្យបានតាមតម្រូវការទីផ្សារ ក៏ដូចជា តម្រូវការរបស់សមាជិក និងរក្សាបាននូវគុណតម្លៃនៃវិជ្ជាជីវៈ ដោយឯកឧត្តម សូមលើកទឹកចិត្តឱ្យសមាជិក សមាជិកាទាំងអស់យកចិត្តទុកដាក់ក្នុងការអនុវត្តប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនិងសូមចូលរួមចុះឈ្មោះជា ASEAN CPA ដើម្បីលើកស្ទួយវិស័យគណនេយ្យនិងសវនកម្មនៅប្រទេសកម្ពុជា និងដើម្បីមុខមាត់របស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងតំបន់អាស៊ាន។

ក្នុងរបៀបវារៈបន្ទាប់ ក្រោយពីស្តាប់នូវបទបង្ហាញរបស់ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិ **វ.គ.ស.ក.** ស្តីពីរបាយការណ៍សម្មភាពការងារឆ្នាំ២០២៣ ក៏ដូចជាបទបង្ហាញរបស់ហេរញ្ញិកនៃ **វ.គ.ស.ក.** ដោយ កញ្ញា **ឆាយ មូរ៉ានីល** និងមតិយល់ឃើញរបស់សវនកររបស់ **វ.គ.ស.ក.** ឆ្នាំ២០២៣ រួចមក សមាជិកក្នុងមហាសន្និបាតទាំងអស់ក៏បានឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៣ និងជ្រើសរើសសវនករសម្រាប់ឆ្នាំ២០២៤។

សម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧ (២០២៤-២០២៨) និងការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានត្រូវបានរៀបចំឡើងជាសម្ងាត់តាមរយៈការិយាល័យត្រួតពិនិត្យសន្លឹកឆ្នោតដែលបានផ្តល់តម្លាភាពជូនសមាជិកទាំងអស់គ្នា។ ជាលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧បេក្ខជន ដែលជាប់ជាសមាជិកក្រុមប្រឹក្សាភិបាលមានរាយនាម ដូចខាងក្រោម៖ (១)កញ្ញា **សុខ ស្រីវដ្ឋា** (២)លោក **ខាវ ហុង** (៣)លោក **ជៀម គីមហួ** (៤)លោក **គង់ ស៊ិនរ៉ា** (៥)លោក **នៅ រ៉េមី** (៦)លោក **ឃុន ដារិទ្ធ** (៧)លោក **គីក សុខវាសនា** (៨)លោក **ស្រេង វុទ្ធី** (៩)លោកស្រី **ស៊ុន គីមហ៊ីន** (១០)លោក **ហួរ វរៈមុត្ត** (១១) កញ្ញា **ជូ សុខឡេង** ។ ជាលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាល លោក **ឃុន ដារិទ្ធ** ជាប់ជាប្រធានក្រុមប្រឹក្សាភិបាល និងលោក **នៅ រ៉េមី** ជាប់ជាអនុប្រធានក្រុមប្រឹក្សាភិបាល នៃ **វ.គ.ស.ក.**។ តាមការស្ម័គ្រចិត្ត កញ្ញា សុង ស្រីវដ្ឋា ត្រូវបានចាត់តាំងជា ហេរញ្ញិកនៃ **វ.គ.ស.ក.**។

ជាចុងបញ្ចប់នៃកម្មវិធី លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលជាប់ឆ្នោតថ្មី បានប្រកាសឆន្ទៈដ៏មុតមាំក្នុងការបន្តការអភិវឌ្ឍ **វ.គ.ស.ក.** ឱ្យកាន់តែមានភាពរីកចម្រើន។







## កិច្ចប្រជុំពិភាក្សាអនឡាញ ស្តីពី វឌ្ឍនភាពការងារក្នុងការរៀបចំវេទិកាគណនេយ្យជាតិឆ្នាំ២០២៤ ក្រោមប្រធានបទ “តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យ ឆ្នាំ២០៣០”



នារសៀលថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ២និង០០នាទី រសៀល លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ**វ.គ.ស.ក.** បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាអនឡាញ ស្តីពី វឌ្ឍនភាពការងារក្នុងការរៀបចំវេទិកាគណនេយ្យជាតិឆ្នាំ២០២៤ ក្រោមប្រធានបទ “**តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យ ឆ្នាំ២០៣០**” ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក និយ័តករគណនេយ្យនិងសវនកម្ម ដោយមានការសហការគាំទ្រ និងចូលរួមពី ថ្នាក់ដឹកនាំនិងក្រុមការងារនៃ **ន.គ.ស.** ថ្នាក់ដឹកនាំនៃ **វ.គ.ស.ក.** ACCA ប្រចាំប្រទេសកម្ពុជា ក្រុមហ៊ុន DFC និងក្រុមហ៊ុន Banhji ផងដែរ។

## កិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា



នៅព្រឹកថ្ងៃព្រហស្បតិ៍ ៦ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១០និង០០នាទី តាមប្រព័ន្ធអនឡាញ លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ កិច្ចប្រជុំធ្វើឡើងដើម្បីពិនិត្យ និងវាយតម្លៃបុគ្គលស្នើសុំចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន រាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំ និងរបាយការណ៍កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៤ផងដែរ។ កិច្ចប្រជុំបានបញ្ចប់ប្រកបដោយផ្លែផ្កានិងកិច្ចសហប្រតិបត្តិការខ្ពស់។

## កិច្ចប្រជុំតាមអនឡាញជាមួយលោក Edward Tanujaya នាយកប្រតិបត្តិនៃ សហព័ន្ធគណនេយ្យករអាស៊ាន (AFA)




នៅព្រឹកថ្ងៃចន្ទ ទី១៥ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០នាទីព្រឹក លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) និងលោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** បានចូលរួមកិច្ចប្រជុំតាមអនឡាញជាមួយលោក Edward Tanujaya នាយកប្រតិបត្តិនៃសហព័ន្ធគណនេយ្យករអាស៊ាន(AFA) ដើម្បីពិភាក្សាលើការពង្រឹងកិច្ចសហប្រតិបត្តិការជាពិសេសលើសិក្ខាសាលាថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីផលប្រយោជន៍ទៅវិញទៅមកក្នុងចំណោមសមាជិក។ កិច្ចប្រជុំតាមប្រព័ន្ធអ៊ីនធឺណិតបានបញ្ចប់ដោយមានកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា និងខ្ពស់។

កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ
"ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ"



នៅព្រឹកថ្ងៃពុធ ៣ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា គ.ស.២០២៤ នៅវិទ្យាស្ថានវ៉ាន់ដា លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានអញ្ជើញចូលរួម និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ "**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**" ជូនសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង**ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន វ៉ាន់ដា។ សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

-ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ

-ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ

-ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យ និងនិស្សិត សរុប ៣៨១រូបនៅសាលប្រជុំនៃវិទ្យាស្ថាន វ៉ាន់ដា។

---

កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ
"ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ"



នៅព្រឹកថ្ងៃអង្គារ ៩ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែសីហា គ.ស.២០២៤ នៅសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានអញ្ជើញចូលរួម និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ "**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**" ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង**ឯកឧត្តមបណ្ឌិត ជួន រតនៈ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

-ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ

-ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ

-ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពីសាស្ត្រាចារ្យ និងនិស្សិត សរុប ១៤០រូប នៅសាលប្រជុំនៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី “ស្តង់ដាសវនកម្មអន្តរជាតិ សម្រាប់សហគ្រាសមិនស្មុគស្មាញនៅកម្ពុជា (ISA for LCE)”



នៅព្រឹកថ្ងៃព្រហស្បត្តិ៍ ៣ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែសីហា គ.ស.២០២៤ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(**វ.គ.ស.ក.**) បានរៀបចំកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ស្តីពី “**ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញនៅកម្ពុជា** (ISA for LCE)” ក្រោមអធិបតីភាព លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** លោក **ជេន ផាត** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្មតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្មនិងជាវាគ្មិនកិត្តិយស លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** ថ្នាក់ដឹកនាំនិងមន្ត្រីនៃ **វ.គ.ស.ក.** និង **ន.គ.ស.** រួមទាំងតំណាងមកពីក្រុមហ៊ុនសវនកម្មដែលជាសមាជិករបស់ **វ.គ.ស.ក.** សរុបជាង៥០រូប។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងអំពី ស្តង់ដា ISA for LCE និងប្រមូលធាតុចូលជូននិយ័តករគណនេយ្យនិងសវនកម្ម អំពីលទ្ធភាពនៃការទទួលយកស្តង់ដានេះមកអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាពជោគជ័យនៅកម្ពុជា។
សិក្ខាសាលានេះបានបញ្ចប់នៅវេលាម៉ោងនៅ១២និង០០នាទីរសៀល នាថ្ងៃខែឆ្នាំដដែល ប្រកបដោយផ្លែផ្កា និងសហប្រតិបត្តិការខ្ពស់។

---

ក្រុមការងាររបស់ CPA Australia North Vietnam និង ន.គ.ស. បានបំពេញទស្សនកិច្ចនៅការិយាល័យ វ.គ.ស.ក. ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងបីឱ្យកាន់តែមានភាពរឹងមាំ



នៅរសៀលថ្ងៃព្រហស្បតិ៍ ១០ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី២៩ ខែសីហា គ.ស. ២០២៤ លោកស្រី Nguyen Thi Bich Hien ប្រធានតំបន់ CPA Australia ប្រចាំវៀតណាមខាងជើង លោក **ជេន ផាត** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម រួមទាំងមន្ត្រីជំនាញ ក្រុមការងាររបស់CPA Australia North Vietnam និង **ន.គ.ស.** បានបំពេញទស្សនកិច្ចនៅការិយាល័យ **វ.គ.ស.ក.** ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងបីឱ្យកាន់តែមានភាពរឹងមាំ។ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** និងក្រុមការងារនៃ **វ.គ.ស.ក.** បានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងសម្តែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះទស្សនកិច្ចក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការនេះ។

---

កម្មវិធីសិក្ខាសាលាស្តីពី “ការរាយការណ៍ព័ត៌មានអំពីចីរភាព ការអនុវត្ត សម្ថតិកម្ម និងសក្តានុពល”



នៅព្រឹកថ្ងៃសុក្រ ១១ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារសុខាភ្នំពេញ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(**វ.គ.ស.ក.**) បានសហការជាមួយ **ន.គ.ស.** និង CPA Australia រៀបចំកម្មវិធីសិក្ខាសាលាស្តីពី “**ការរាយការណ៍ព័ត៌មានអំពីចីរភាព ការអនុវត្ត សម្ថតិកម្ម និងសក្តានុពល**” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** លោក **ជេន ផាត** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** កញ្ញា Hien Nguyen, Reginal Manager, CPA Australia North Vietnam។ សិក្ខាសាលានេះមានការចូលរួមពីសមាជិករបស់ **វ.គ.ស.ក.** សមាជិករបស់ CPA Australia នៅកម្ពុជា តំណាងស្ថាប័ន ឬក្រសួងពាក់ព័ន្ធ និងមន្ត្រីជំនាញសរុបប្រមាណជាង១០០រូប។ ក្នុងនោះផងដែរ

លោក **ជា ឆួន** នាយកផ្នែកអប់រំនៃ **វ.គ.ស.ក.** ក៏ជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សា ស្តីពី កាលានុវត្តភាព បញ្ហាប្រឈម ក្នុងការអនុវត្តស្តង់ដានេះ។ កម្មវិធីសិក្ខាសាលានេះត្រូវបានប្រារព្ធឡើងក្នុងគោលបំណង÷

១.រាយការណ៍ព័ត៌មានអំពីចីរភាព ការអនុវត្ត សម្មតិកម្ម និងសក្តានុពល និង

២.បញ្ជ្រាបការយល់ដឹងបន្ថែមអំពីបច្ចុប្បន្នភាពថ្មីៗ និងបញ្ហាប្រឈមនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ ប្រកបដោយចីរភាព។

សិក្ខាសាលាបានបញ្ចប់នាវេលាម៉ោង១២និង១០នាទីរសៀល នាថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយផ្លែផ្កា និងកិច្ចសហប្រតិបត្តិការខ្ពស់។

---

កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ"



នៅព្រឹកថ្ងៃសៅរ៍ ៥ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា គ.ស.២០២៤ នៅសាកលវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានអញ្ជើញចូលរួម និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ "**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**" ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ុ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង **ឯកឧត្តម សាស្ត្រាចារ្យ ធុំ សារាវុធ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង។

សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

-ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ

-ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ និង

-ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរង់សវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពី ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មន្ត្រី សិស្ស និងនិស្សិត សរុប ៣៥០រូបនៅសាលប្រជុំនៃសាកលវិទ្យាល័យស្វាយរៀង។

សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១២និង០០នាទីរសៀល ប្រកបដោយផ្លែផ្កា និងកិច្ចសហប្រតិបត្តិការខ្ពស់។

---

កិច្ចប្រជុំ ស្តីពី វឌ្ឍនភាពការងារ និងការងារត្រូវរៀបចំបន្ត សម្រាប់កម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ក្រោមប្រធានបទ "តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០"



នារសៀលថ្ងៃចន្ទ ៥ កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែតុលា គ.ស.២០២៤ នៅសាលប្រជុំនៃនិយ័តគណនេយ្យនិងសវនកម្ម លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងលោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមកិច្ចប្រជុំក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ុ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ស្តីពី វឌ្ឍនភាពការងារ និងការងារត្រូវរៀបចំបន្ត សម្រាប់កម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ក្រោមប្រធានបទ "**តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០**" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ កិច្ចប្រជុំត្រូវបានធ្វើឡើងដើម្បីត្រួតពិនិត្យ និងវាយតម្លៃ នូវវឌ្ឍនភាពការងារ និងសកម្មភាពនានាក្នុងការរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ និងដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពជោគជ័យរបស់វេទិកាជាតិគណនេយ្យនាពេលខាងមុខនេះ។ កិច្ចប្រជុំនេះមានការចូលរួមដោយ លោក លោកស្រី អគ្គនាយករងនៃ **ន.គ.ស.** ថ្នាក់ដឹកនាំមកពីវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ACCA ប្រចាំប្រទេសកម្ពុជា ក្រុមហ៊ុន DFC ក្រុមហ៊ុន Banhji និងក្រុមការងាររបស់ **ន.គ.ស.** ផងដែរ។

វេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ក្រោមប្រធានបទ "តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០"



នាថ្ងៃព្រហស្បតិ៍-សុក្រ ១៥និង១៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧និង១៨ ខែតុលា គ.ស.២០២៤ និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) សហការជាមួយ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង ACCA Cambodia បានរៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ក្រោមប្រធានបទ "**តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០**" នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ កម្មវិធីវេទិកាជាតិគណនេយ្យនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ទី តាឃី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អមដោយ **ឯកឧត្តម ប៊ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម។ កម្មវិធីវេទិកាជាតិគណនេយ្យដែលប្រារព្ធឡើងក្នុងឆ្នាំដំបូងនេះ បានផ្តោតជាសំខាន់ទៅលើ÷

- ទិដ្ឋភាពគោលនយោបាយ បទប្បញ្ញត្តិ និងផែនការអភិវឌ្ឍសម្រាប់វិស័យហិរញ្ញវត្ថុ គណនេយ្យ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០
- បរិវត្តកម្មឌីជីថលនិងនវានុវត្តន៍ក្នុងសេវាគណនេយ្យនិងសវនកម្ម
- ការដាក់ឱ្យដំណើរការថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- លទ្ធផលនៃការសិក្សាស្រាវជ្រាវពីការប្រើប្រាស់បច្ចេកវិទ្យារបស់ក្រុមហ៊ុនគណនេយ្យ និងសវនកម្មក្នុងប្រទេសកម្ពុជា
- ការចែករំលែកនូវបទពិសោធ កាលានុវត្តភាព និងបញ្ហាប្រឈម
- លទ្ធផលនៃការសិក្សាស្តីអំពីអនាគតនៃមុខងារហិរញ្ញវត្ថុក្នុងឆ្នាំ ២០៣០
- សារៈសំខាន់នៃការអភិវឌ្ឍជំនាញ និងគុណវុឌ្ឍិដើម្បីសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០

ក្នុងនោះដែរ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** និងលោក **ជា ឆួន** នាយកផ្នែកអប់រំនៃ **វ.គ.ស.ក.** ក៏ជាវាគ្មិនកិត្តិយសក្នុងការធ្វើបទបង្ហាញនិងកិច្ចពិភាក្សាក្នុងកម្មវិធីវេទិកាជាតិគណនេយ្យនេះផងដែរ។

កម្មវិធីវេទិកាជាតិនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ព្រមទាំងឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនានា និងមានការចូលរួមពីសំណាក់ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ប្រមាណ២,៦៥០នាក់។

កិច្ចប្រជុំលើកទី៤១ នៃក្រុមការងារអ្នកជំនាញការអន្តររដ្ឋាភិបាលស្តីពីស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ



នាថ្ងៃពុធ-សុក្រ ៦-៨ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦-៨ ខែវិច្ឆិកា គ.ស.២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** និងគណៈប្រតិភូរបស់និយ័តករគណនេយ្យនិងសវនកម្ម ដឹកនាំដោយ **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំលើកទី៤១ នៃក្រុមការងារអ្នកជំនាញការអន្តររដ្ឋាភិបាលស្តីពីស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ ដែលបានបង្កើតឡើងដោយ ECOSOC នាឆ្នាំ១៩៨៣។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ (International Standard of Accounting and Reporting) ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។ កិច្ចប្រជុំនេះបានធ្វើឡើងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយផ្តោតសំខាន់ទៅលើប្រធានបទសំខាន់ចំនួន ២÷

1) ការត្រួតពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្ត ការរាយការណ៍ព័ត៌មានចីរភាព និងការអះអាងនិងក្រមសីលធម៌

2) ការរួមបញ្ចូលការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានចីរភាពនៃស្ថាប័ន ដោយប្រើប្រាស់បច្ចេកវិទ្យា

សូមជម្រាបផងដែរថា កម្ពុជានឹងត្រៀមខ្លួនអនុវត្តស្តង់ដាការរាយការណ៍ព័ត៌មានចីរភាព ដើម្បី សម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ឆ្នាំ២០១៦-២០៣០។

---

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន លើកទី១៣៩




នាថ្ងៃសៅរ៍ ៨រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា គ.ស. ២០២៥ នៅទីក្រុងដាវ៉ាវ នាប្រទេសហ្វីលីពីន លោក **សៅ អ៊ើមី** អនុប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** តំណាងលោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** និងលោកស្រី **សារុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ានលើកទី១៣៩ដែលរៀបចំដោយវិទ្យាស្ថានគណនេយ្យករជំនាញហ្វីលីពីន (PICPA)។ កិច្ចប្រជុំនេះមានគោលបំណង ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងអាស៊ាន និងការលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់អនាគតនៃវិជ្ជាជីវៈគណនេយ្យ។

ព្រឹត្តិការណ៍នេះបានផ្តល់នូវវេទិកាដ៏ល្អសម្រាប់កិច្ចពិភាក្សាប្រកបដោយអត្ថន័យជាមួយសមាជិកក្នុងតំបន់ ដែលពេលនោះ **វ.គ.ស.ក.** ក៏បានចែករំលែកការត្រៀមខ្លួនក្នុងការក្លាយជាសមាជិកពេញសិទ្ធិនៃសហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) និងឆន្ទៈក្នុងការជំរុញវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនោះ លោក **សៅ អ៊ើមី** ក៏បានជួបពិភាក្សាជាមួយ តំណាង ACCA និង IFAC ស្តីពីការលើកកម្ពស់សមត្ថភាពរបស់គណនេយ្យជំនាញនៅកម្ពុជា។ កិច្ចពិភាក្សាទាំងនេះក៏បានផ្តោតជាសំខាន់លើការរក្សាគណនេយ្យករជំនាញនាំមុខក្នុងវិស័យនេះ និងការដាក់បញ្ចូលរបាយការណ៍ប្រកបដោយចីរភាពទៅក្នុងការកិច្ចការគណនេយ្យ ដោយផ្តល់សិទ្ធិដល់គណនេយ្យករឱ្យដឹកនាំនិងផ្តួចផ្តើមគំនិតលើការងារបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។

ក្នុងនាម **វ.គ.ស.ក.** លោក **សៅ អ៊ើមី** ក៏បានបញ្ជាក់ផងដែរថា កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន លើកទី១៤០ និងសន្និសីទថ្នាក់តំបន់នៅខែឧសភា ឆ្នាំ២០២៥។

កិច្ចប្រជុំបានបញ្ចប់ដោយជោគជ័យដោយបានពង្រឹងកិច្ចសហប្រតិបត្តិការ និងជំរុញវិជ្ជាជីវៈគណនេយ្យនៅទូទាំងអាស៊ាន។ **វ.គ.ស.ក.** សម្តែងនូវអំណរគុណដល់វិទ្យាស្ថានគណនេយ្យករជំនាញហ្វីលីពីន សម្រាប់ការរៀបចំព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះហើយក៏ទន្ទឹងរង់ចាំស្វាគមន៍ មកកាន់ប្រទេសកម្ពុជាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ានលើកទី ១៤០ និងសន្និសីទថ្នាក់តំបន់ក្នុងខែឧសភា ឆ្នាំ២០២៥។

លោក ឃុន ដារិទ្ធ ប្រធានក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.) និងលេខាធិការដ្ឋាននៃ វ.គ.ស.ក. បានទទួលស្វាគមន៍ភ្ញៀវកិត្តិយសពីធនាគារពិភពលោក




នាព្រឹកថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៤ លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងលេខាធិការដ្ឋាននៃ **វ.គ.ស.ក.** បានទទួលស្វាគមន៍ភ្ញៀវកិត្តិយសពីធនាគារពិភពលោក រួមមានលោកស្រី Patricia McKenzie លោក Moad M. Alrubaidi និងលោក Sophear Khiev សម្រាប់ការពិភាក្សាប្រកបដោយផ្លែផ្កាស្តីពីការជំរុញការអនុវត្តគណនេយ្យ និងសវនកម្មនៅកម្ពុជា។ ប្រធានបទសំខាន់ៗរួមមានការធ្វើបច្ចុប្បន្នភាពលើកម្មវិធី CPD និង ATQ ក៏ដូចជាការយល់ដឹងអំពីកម្មវិធី CPA ជាតិ។

---

ចូលរួមជាភ្ញៀវកិត្តិយស ក្នុងកម្មវិធី "ប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើម"



នាព្រឹកថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០២៤ លោកស្រី **សាខុធ ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**)និង លោក **ជា ឆួន** នាយកផ្នែកអប់រំនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងកម្មវិធី "**ប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើម**" នៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងអបអរសាទរដល់និស្សិតឆ្នើមប្រចាំសាកលវិទ្យាល័យ ដែលបានសិក្សា និងប្រឡងជាប់កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)។ កម្មវិធីនេះមានការចូលរួមពីសាស្ត្រាចារ្យនិងនិស្សិតប្រមាណ៧៥រូប នៅសាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា និងបានបញ្ចប់នៅវេលាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កានិងភាពជោគជ័យខ្ពស់។

---

កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលសម្រាប់សគ្រាសប្រកបវិជ្ជាជីវៈធុនតូចនិងមធ្យម"



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី "**ផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលសម្រាប់សគ្រាសប្រកបវិជ្ជាជីវៈធុនតូចនិងមធ្យម**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** លោកស្រី **សាខុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** និងមានការសហការចូលរួមជាវាគ្មិនកិត្តិយស លោក **ស៊ឹម ចាន់គិរីរ័ត្ន** ស្ថាបនិក និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន Banhji ព្រមទាំងលោក លោកស្រី តំណាងពីក្រុមហ៊ុនគណនេយ្យ និងសវនកម្ម សរុបចំនួន៧៤រូប។ សិក្ខាសាលានេះត្រូវបានធ្វើឡើងក្នុងគោលបំណង÷

១. ដើម្បីផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង និងការត្រៀមខ្លួន ស្តីពី ការរៀបចំផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលសម្រាប់សហគ្រាសប្រកបវិជ្ជាជីវៈធុនតូច និងមធ្យម ដែលជាក្រុមហ៊ុនគណនេយ្យ និងសវនកម្ម

២. ការផ្តល់ធាតុចូលជាមូលដ្ឋានក្នុងការកសាងបាននូវផែនទីបង្ហាញផ្លូវនៃការចាប់យកឌីជីថលរបស់ SMP

៣. លើកទឹកចិត្តអ្នកចូលរួមដើម្បី ចែករំលែកនូវបញ្ហាប្រឈមទាំងអស់គ្នាតាមរយៈការទទួលចាប់យក និងបរិវត្តកម្មឌីជីថល ដើម្បីអាចទទួលបាននូវឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារ

៤. និងជួយបង្កើនប្រសិទ្ធភាពប្រតិបត្តិការរវាងអ្នកអនុវត្ត និងស្ថាប័នពាក់ព័ន្ធ ក្នុងការធ្វើបរិវត្តកម្មឌីជីថលឱ្យខានតែបានពីបច្ចុប្បន្នដល់ឆ្នាំ២០៣៥។

សិក្ខាសាលាពិគ្រោះយោបល់នេះត្រូវបានបញ្ចប់នូវវេលាម៉ោង១២និង០០នាទីរសៀលប្រកបដោយផ្លែផ្កានិងសហប្រតិបត្តិការខ្ពស់។

កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ
“ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នៅព្រឹកថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែធ្នូ គ.ស.២០២៤ នៅសាកលវិទ្យាល័យបៀលប្រាយ លោកស្រី **សាធុច ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងមន្ត្រីជំនាញនៃ**វ.គ.ស.ក.** បានអញ្ជើញចូលរួមនិងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង លោក **ឌី ដាវុឌ្ឍ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យបៀលប្រាយ ។

សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

១. ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ
២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ និង
៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពី ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មន្ត្រី សិស្ស និងនិស្សិត សរុប១៥០រូបនៅសាលប្រជុំនៃសាកលវិទ្យាល័យបៀលប្រាយ។ សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១២និង០០នាទីរសៀល ប្រកបដោយផ្លែផ្កា និងកិច្ចសហប្រតិបត្តិការខ្ពស់។

---

កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ
“ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
និងបទប្បញ្ញត្តិពាក់ព័ន្ធ”



នៅព្រឹកថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ គ.ស.២០២៤ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង លោកស្រី **សាធុច ដាលី** នាយកប្រតិបត្តិនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងមន្ត្រីជំនាញនៃ **វ.គ.ស.ក.** បានអញ្ជើញចូលរួម និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ “**ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ**” ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាព លោកស្រី **នាន បូនី** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង លោកបណ្ឌិត **លី សុខហេង** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ហោ ប៉េង** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។

សិក្ខាសាលានេះរៀបចំឡើងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចជាសារវន្តចំនួនបីរួមមាន÷

- ការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ និង
- ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលានេះមានការចូលរួមពី ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មន្ត្រី សិស្ស និងនិស្សិត សរុប១៧០រូប នៅសាលប្រជុំនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១០និង៣០នាទីព្រឹក ប្រកបដោយផ្លែផ្កា និងកិច្ចសហប្រតិបត្តិការខ្ពស់។

## កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងវគ្គបណ្ដុះបណ្ដាលរបស់ វ.គ.ស.ក.

វគ្គតម្រង់ទិសស្ដីពី
“ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នាព្រឹកថ្ងៃសុក្រ ៩ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដាបានរៀបចំវគ្គតម្រង់ទិសស្ដីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” សម្រាប់និស្សិតប្រមាណ៦០រូប នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិត។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្ដល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សានិងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅវេលាម៉ោង១២និង៣០នាទីរសៀល នាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

---

កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី
“ការណែនាំលើការបង្រៀនកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នារសៀលថ្ងៃសុក្រ ៩ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤**វ.គ.ស.ក.** បានរៀបចំកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី “**ការណែនាំលើការបង្រៀនកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” ដល់លោកគ្រូអ្នកគ្រូចំនួន ១៤នាក់នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ គោលបំណងនៃការបណ្ដុះបណ្ដាលគ្រូបង្គោលនេះគឺដើម្បីជំរុញអត្រាប្រឡងជាប់របស់និស្សិត និងរួមគ្នាបង្កើតរបៀបនៃការរៀននិងការបង្រៀនថ្មីនៃវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។ លោក **ជា ឆួន** នាយកផ្នែកអប់រំ **វ.គ.ស.ក.** គឺជាគ្រូបណ្ដុះបណ្ដាលនៃកម្មវិធីនេះ និងបានធ្វើបទបង្ហាញអំពី÷

- ទិដ្ឋភាពទូទៅនៃ **វ.គ.ស.ក.** និងបច្ចុប្បន្នភាពនៃវិស័យគណនេយ្យនិងសវនកម្ម
- កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)
- ការរៀន និងការបង្រៀនក្នុងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)

វគ្គសិក្សានេះបានបញ្ចប់នៅវេលាម៉ោង ៤ និង៣០នាទីល្ងាច នាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កានិងភាពរីករាយក្រៃលែង។

វគ្គតម្រង់ទិស
ស្តីពី "គន្លឹះដើម្បីក្លាយជគណនេយ្យករ
ដ៏ជំនាញ"



នៅថ្ងៃសៅរ៍ ៣ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានរៀបចំវគ្គតម្រង់ទិសស្តីពី "**គន្លឹះដើម្បីក្លាយជាគណនេយ្យករដ៏ជំនាញ**" សម្រាប់អ្នកចូលរួមប្រមាណ ២១៥រូប នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកចូលរួម។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់អ្នកចូលរួមដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៣. ការជំរុញឱ្យមានការចុះឈ្មោះចូលរៀន និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. និងការណែនាំអំពីរបៀបសិក្សានិងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅវេលាម៉ោង១២និង០០នាទីរសៀល នាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

វគ្គតម្រង់ទិសស្តីពី
"ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) "



នាថ្ងៃព្រហស្បតិ៍ ១៥ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ បានរៀបចំវគ្គតម្រង់ទិសស្តីពី "**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ) " សម្រាប់និស្សិតក្នុងឆ្នាំសិក្សាថ្មី ពីរវេន គឺវេនព្រឹក និងល្ងាច នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិត។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សានិងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាស្តីពី “ការអប់រំផ្នែកគណនេយ្យក្នុងយុគសម័យថ្មី”



នាព្រឹកថ្ងៃសុក្រ ១ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ លោក **ជា ឆួន** នាយកផ្នែកអប់រំនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានសហការរៀបចំកម្មវិធីសិក្ខាសាលាស្តីពី “**ការអប់រំផ្នែកគណនេយ្យក្នុងយុគសម័យថ្មី**” នៅវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ សម្រាប់សិស្សនិស្សិតនៅវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ។ ក្នុងនោះដែរ លោក **ជា ឆួន** ក៏ជាវាគ្មិនកិត្តិយសនិងបានធ្វើបទបង្ហាញស្តីពី អត្ថប្រយោជន៍នៃកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ ជូនសិស្សនិស្សិតដែលបានចូលរួមផងដែរ។ កម្មវិធីនេះពិតជាទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិតដែលបានចូលរួម។ ជាលទ្ធផល សិក្ខាសាលានេះផ្តល់ផលប្រយោជន៍ដល់អ្នកចូលរួមដូចជា÷

១. យល់ដឹងអំពីការសិក្សាជំនាញគណនេយ្យក្នុងយុគសម័យថ្មី
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ និងអត្ថប្រយោជន៍នៃកម្មវិធីនេះ
៣. យល់ដឹងបន្ថែមអំពីតម្រូវការគណនេយ្យករក្នុងទីផ្សារនាពេលបច្ចុប្បន្ន

កម្មវិធីនេះត្រូវបានបញ្ចប់នៅវេលាម៉ោង១១និង៥០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

---

## សិក្ខាសាលាអនឡាញស្តីពី “បច្ចុប្បន្នភាពពន្ធ”




វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំសិក្ខាសាលាអនឡាញស្តីពី “**បច្ចុប្បន្នភាពពន្ធ**” ដោយវាគ្មិនកិត្តិយស លោកស្រី **ផេង សុវិជ្ជានី** ស្ថាបនិក និងជាដៃគូគ្រប់គ្រង និងលោក **ខួន វ៉ាន់ដេត** ទីប្រឹក្សាពន្ធជាន់ខ្ពស់នៅក្រុមហ៊ុន Davies SM Attorneys at Law, Cambodia ថ្ងៃពុធ ទី 0៧ ខែកុម្ភៈ ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:00 នាទីព្រឹក ដល់ ១១: ៣0 នាទីព្រឹក។
សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក**វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។
សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៧00នាក់ ។

---

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នាល្ងាចថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) និងវិទ្យាស្ថាន វ៉ាន់ដា បានសហការរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ**(ATQ)” សម្រាប់និស្សិតសរុបប្រមាណជាង ១៧រូប នៅវិទ្យាស្ថាន វ៉ាន់ដា ដើម្បីជម្រុញអត្រាប្រឡងជាប់ជាស្ថាពររបស់និស្សិតឱ្យបានខ្ពស់។ កម្មវិធីនេះត្រូវបានបញ្ចប់នៅវេលាម៉ោង៨និង00នាទីល្ងាចនាថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី “បច្ចុប្បន្នភាពនៃគណនេយ្យ”





នារសៀលថ្ងៃពុធ-ព្រហស្បតិ៍ ៥និង៦ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ១៤និង១៥ ខែកុម្ភៈ ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្រោមប្រធានបទ “**បច្ចុប្បន្នភាពនៃគណនេយ្យ**” សម្រាប់សាស្ត្រាចារ្យប្រមាណ ២៧រូបដែលជាគ្រូបង្គោលមកពី១៣ស្ថាប័នអប់រំផ្សេងៗគ្នា។ វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមបង្រៀនដោយលោកគ្រូ **ឡុង ប៊ុរិន្ទ** ជាគ្រូបង្គោលដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងអាជីពគណនេយ្យ។ ជាលទ្ធផល វគ្គបណ្តុះបណ្តាលនេះបានចូលរួមពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូបន្ថែមឱ្យ÷

១. យល់ដឹងកាន់តែច្បាស់អំពីបច្ចុប្បន្នភាពនៃគណនេយ្យ

២. ធ្វើឱ្យការបង្រៀនមុខវិជ្ជាគណនេយ្យកាន់តែមានប្រសិទ្ធភាពខ្ពស់តាមរយៈការផ្សារភ្ជាប់ចំណេះដឹងនឹងការអនុវត្តជាក់ស្តែង

៣. ជួយជំរុញឱ្យកម្រិតប្រឡងជាប់របស់សិស្សនិស្សិតទទួលបានភាគរយខ្ពស់ក្នុងការប្រឡងបច្ចេកទេសគណនេយ្យ (ATQ)

កម្មវិធីនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាអនឡាញស្តីពី “រលកនៃការវាយប្រហារតាមអ៊ីនធឺណិត÷ ការផ្តោតលើស្ថាប័នហិរញ្ញវត្ថុ”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំសិក្ខាសាលាអនឡាញស្តីពី “**រលកនៃការវាយប្រហារតាមអ៊ីនធឺណិត៖ ការផ្តោតលើស្ថាប័នហិរញ្ញវត្ថុ**” ដោយវាគ្មិនកិត្តិយស លោកបណ្ឌិត **វង្ស សុខា** នាយកប្រតិបត្តិនៃក្រុមហ៊ុន Technovage Solution Co., Ltd. នៅថ្ងៃសុក្រទី ២៣ ខែកុម្ភៈ ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:00 នាទីព្រឹក ដល់ ១១: ៣០នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៣០០នាក់ ។

## វគ្គណែនាំសមាជិកដំបូង ( Membership Induction Course)







វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គណែនាំសមាជិកដំបូង (Induction Course) របស់ខ្លួនចំនួនបីពេល សម្រាប់សមាជិកថ្មីឆ្នាំ២០២៤ សរុប៣០រូប នៅបន្ទប់ប្រជុំនៃ **វ.គ.ស.ក.** កាលពីថ្ងៃទី២១ និង២២ ខែមីនា ឆ្នាំ២០២៤។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងការយល់ដឹងបន្ថែមអំពីវិទ្យាស្ថាន សមាជិកភាពនិងកាតព្វកិច្ច គោលការណ៍នៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) កម្មវិធីបច្ចេកទេសគណនេយ្យ (ATQ) ជូនដល់សមាជិករបស់ខ្លួន និងជាពិសេសការអបអរសាទរដល់សមាជិកថ្មីផងដែរ។ លទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះ សមាជិកថ្មីដែលបានចូលរួមទាំងអស់មានមោទនភាពដែលបានចូលរួមជាសមាជិករបស់ **វ.គ.ស.ក.** និងប្តេជ្ញាចូលរួមអភិវឌ្ឍខ្លួនឯងបន្ថែមជាប្រចាំជាមួយវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំដោយ **វ.គ.ស.ក.** ។ កម្មវិធីនេះត្រូវបានបញ្ចប់ ប្រកបដោយផ្លែផ្កា ភាពរីករាយ និងចំណងទាក់ទងរវាងគ្នានិងគ្នាកាន់តែរឹងមាំ។

## សិក្ខាសាលាស្តីពី “តម្លៃផ្ទេរប្រាក់”



វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយមានការសហការពី ALLNISON AUDITING AND CONSULTING CO., LTD. បានរៀបចំសិក្ខាសាលាស្តីពី “**តម្លៃផ្ទេរប្រាក់**” នៅថ្ងៃអង្គារ ទី ២ ខែមេសា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:00 នាទីព្រឹក ដល់ម៉ោង ១១:00 នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។
សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៤៦០នាក់ ។

## សិក្ខាសាលាស្តីពី “CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម÷ ឧបករណ៍ហិរញ្ញវត្ថុ”



វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយមានការសហការពី Crowe Malaysia PLT ។ បានរៀបចំសិក្ខាសាលាស្តីពី “CIFRS **សម្រាប់សហគ្រាសធុនតូច និងមធ្យម÷ ឧបករណ៍ហិរញ្ញវត្ថុ**” នៅថ្ងៃសុក្រ ទី ៣ ខែឧសភា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីរសៀល។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។
សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៥០០នាក់ ។

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី “QuickBooks Online Global Edition Best Practice & Technical Sharing”





នារសៀលថ្ងៃព្រហស្បតិ៍-សុក្រ ២និង៣ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ៩និង១០ ខែឧសភា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្រោមប្រធានបទ “QuickBooks Online Global Edition Best Practice & Technical Sharing” សម្រាប់សាស្ត្រាចារ្យប្រមាណ២០រូប ដែលជាគ្រូបង្គោលមកពី១៣ស្ថាប័នអប់រំផ្សេងៗគ្នា។ វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមបង្រៀនដោយលោកគ្រូ **សូរ តារា**។ ជាលទ្ធផល វគ្គបណ្តុះបណ្តាលនេះបានចូលរួមពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូបន្ថែមឱ្យ÷

១- យល់ដឹងកាន់តែច្បាស់អំពី QuickBooks online

២- បង្រៀនមុខវិជ្ជា QuickBooks ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់តាមរយៈការផ្សារភ្ជាប់ចំណេះដឹង ទៅនឹងការអនុវត្តជាក់ស្តែង

៣- ជួយជំរុញឱ្យកម្រិតប្រឡងជាប់របស់សិស្សនិស្សិតទទួលបានភាគរយខ្ពស់ក្នុងការប្រឡងបច្ចេកទេសគណនេយ្យ (ATQ)

កម្មវិធីនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នៅថ្ងៃអង្គារ ៦ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ**(ATQ)” សម្រាប់និស្សិតប្រមាណ៣៧រូប នៅសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិត។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សា និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

---

## សិក្ខាសាលាស្តីពី “ក្រមសីលធម៌”




វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ជាមួយនឹងការសហការពីក្រុមហ៊ុន PKF Covenant Co., Ltd. បានរៀបចំសិក្ខាសាលាស្តីពី “**ក្រមសីលធម៌**” នៅថ្ងៃចន្ទ ទី ៣ ខែមិថុនា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ ១១:៣០នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៤០០នាក់ ។

---

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នៅថ្ងៃអង្គារ ១៣ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ**(ATQ)” សម្រាប់និស្សិតប្រមាណ៤៣រូប នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិត។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ និងការប្រើប្រាស់អែប KICPAA
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សា និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នាព្រឹក ថ្ងៃសៅរ៍ ២ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រអេស៊ីលីដា បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” សម្រាប់សិក្ខាកាមនៅមជ្ឈមណ្ឌលហ្វឹកហ្វឺន និងអភិវឌ្ឍន៍សហគ្រិនភាព នៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ និងការប្រើប្រាស់ KICPAA App
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សា និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅម៉ោង ១១: ៣០ព្រឹក នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នៅថ្ងៃអង្គារ ៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” ចំនួនពីរវេន គឺវេនព្រឹក និងល្ងាច សម្រាប់និស្សិតប្រមាណ៨០រូប នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ និងការប្រើប្រាស់អែប KICPAA
៣. ការជំរុញឱ្យមានការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៤. ការណែនាំអំពីរបៀបសិក្សា និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាស្តីពី “IFRS S1 and S2”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយមានកិច្ចសហការពីក្រុមហ៊ុន Grant Thornton (Cambodia) Ltd. និង Grant Thornton Australia Limited បានរៀបចំសិក្ខាសាលាស្តីពី “IFRS S1 and S2” នៅថ្ងៃសុក្រ ទី ១៤ ខែមិថុនា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩: ៣០នាទីព្រឹក ដល់ ១១: ៣០នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន៥០០នាក់ ។

## វគ្គតម្រង់ទិសស្តីពី “គន្លឹះដើម្បីក្លាយជាអ្នកជំនាញគណនេយ្យនិងហិរញ្ញវត្ថុ”



នាព្រឹកថ្ងៃសៅរ៍ ៨ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានរៀបចំវគ្គតម្រង់ទិសស្តីពី “**គន្លឹះដើម្បីក្លាយជាអ្នកជំនាញគណនេយ្យនិងហិរញ្ញវត្ថុ**” សម្រាប់អ្នកចូលរួមប្រមាណ៤៣រូប នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ កម្មវិធីនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកចូលរួម។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់អ្នកចូលរួមដូចជា÷

១. យល់ដឹងបន្ថែមពីគន្លឹះក្នុងការត្រៀមខ្លួនដើម្បីក្លាយទៅជាអ្នកជំនាញគណនេយ្យ និងហិរញ្ញវត្ថុ

២. យល់ដឹងពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

៣. ការជំរុញឱ្យមានការចុះឈ្មោះចូលរៀន និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ។

បន្ថែមពីនេះ លោកនាយកផ្នែកអប់រំ ក៏បានចូលរួមអបអរនិងថតរូបអនុស្សាវរីយជាមួយសិក្ខាកាមដែលបញ្ចប់ថ្នាក់TQ1 ផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅវេលាម៉ោង១១និង០០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

---

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នាល្ងាចថ្ងៃព្រហស្បតិ៍ ១៣ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” ជូននិស្សិតប្រមាណ៣៣រូប នៅវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។ កម្មវិធីនេះត្រូវបានធ្វើឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់និស្សិតអំពីបច្ចុប្បន្នភាពគណនេយ្យនិងតម្រូវការនៃអាជីពគណនេយ្យ ក៏ដូចជាណែនាំឱ្យនិស្សិតយល់ដឹងពីវិធីសាស្ត្រសិក្សានិងជំរុញឱ្យការចុះឈ្មោះប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ផងដែរ។ កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយភាពជោគជ័យនិងផ្លែផ្កា។

---

## សិក្ខាសាលាស្តីពី “Information Security Audit”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) ដោយមានកិច្ចសហការពីក្រុមហ៊ុន Deloitte (Cambodia) Co., Ltd. បានរៀបចំសិក្ខាសាលាស្តីពី “Information Security Audit” នៅថ្ងៃសុក្រ ទី ៥ ខែកក្កដា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:០០នាទីព្រឹក ដល់ ១១:៣០នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន១០០នាក់។

## វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី “Value Chain Finance”





នាថ្ងៃទី ១១និង១២ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី ១៦និង១៧ ខែកក្កដា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្រោមប្រធានបទ “Value Chain Finance” សម្រាប់សាស្ត្រាចារ្យប្រមាណ ២៦រូបដែលជាគ្រូបង្គោល មកពី១២ស្ថាប័នអប់រំផ្សេងៗគ្នា។ វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមបង្រៀនដោយលោកគ្រូ **ឡុង បូរិន្ទ** ជាគ្រូបង្គោលដែលមានបទពិសោធន៍ជាច្រើនឆ្នាំពាក់ព័ន្ធនឹងគណនេយ្យនិងហិរញ្ញវត្ថុ។ ជាលទ្ធផល វគ្គបណ្តុះបណ្តាលនេះបានចូលរួមពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូឱ្យយល់ដឹងកាន់តែច្បាស់អំពីតួនាទីនៃ Value Chain Finance ក្នុងវិស័យធុរកិច្ចនាពេលបច្ចុប្បន្ន។កម្មវិធីនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាស្តីពី “ISQM 1, ISQM 2 និង ISA 220”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយមានកិច្ចសហការពីក្រុមហ៊ុន Crowe (KH) Co., Ltd. និង Crowe Malaysia PLT បានរៀបចំសិក្ខាសាលាស្តីពី “ISQM 1, ISQM 2 និង ISA 220” នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ ទី១៨ & ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:00នាទីព្រឹក ដល់ ៥:00 នាទីល្ងាច នៅសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះប្រព្រឹត្តទៅដោយជោគជ័យ ដោយមានក្តីរំភើប និងការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកចូលរួមចំនួន ៤៧ នាក់ដែលជាសមាជិក **វ.គ.ស.ក.** និយ័តករគណនេយ្យ និងសវនកម្ម និយ័តករមូលបត្រកម្ពុជា ធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងឧស្សាហកម្មផ្សេងៗទៀត។

## វគ្គតម្រង់ទិសស្តីពី “ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ)”



នៅល្ងាចថ្ងៃចន្ទ ២ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងវិទ្យាស្ថាន វ៉ាន់ដា បានរៀបចំវគ្គតម្រង់ទិសស្តីពី “**ការរៀន និងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ** (ATQ)” សម្រាប់និស្សិតប្រមាណ ២០រូប នៅវិទ្យាស្ថាន វ៉ាន់ដា។ ជាលទ្ធផល វគ្គតម្រង់ទិសនេះបានផ្តល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ

២. យល់ដឹងបន្ថែមអំពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ

៣. យល់ដឹងពីរបៀបត្រៀមខ្លួនមុនពេលប្រឡង

៤. ការណែនាំអំពីរបៀបសិក្សា និងប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យឱ្យទទួលបានលទ្ធផលល្អផងដែរ។

កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាស្ដីពី “ Hot Accounting Issues in the Banking Industry”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) ជាមួយនឹងការសហការពីក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd. បានរៀបចំសិក្ខាសាលាស្ដីពី “ Hot Accounting Issues in the Banking Industry” នៅថ្ងៃសុក្រ ទី ១៦ ខែសីហា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ ១១:៣០ ព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត(CPD) ដែលរៀបចំឡើងសម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។
សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន១០០នាក់។

---

## កម្មវិធីចែករំលែកចំណេះដឹងស្ដីពី “ការវិវត្តវិស័យគណនេយ្យនៅកម្ពុជា”



នៅល្ងាចថ្ងៃព្រហស្បតិ៍ ១០ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែសីហា គ.ស. ២០២៤វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងសាកលវិទ្យាល័យបៀលប្រាយបានរៀបចំកម្មវិធីចែករំលែកចំណេះដឹងស្ដីពី “**ការវិវត្តវិស័យគណនេយ្យនៅកម្ពុជា**” ដោយមានការចូលរួម ពីវាគ្មិនកិត្តិយស លោក **ជា ឆួន** នាយកផ្នែកអប់រំនៃ **វ.គ.ស.ក.**។ សិក្ខាសាលានេះទទួលជោគជ័យ ដោយមានការចូលរួមពីនិស្សិតប្រមាណ៣០រូប នៅសាកលវិទ្យាល័យបៀលប្រាយ។ ជាលទ្ធផលសិក្ខាសាលានេះបានផ្ដល់ផលប្រយោជន៍ដល់សិស្សនិស្សិតដូចជា÷

១. យល់ដឹងបន្ថែមទៅលើសារសំខាន់នៃគណនេយ្យ និងអាជីពគណនេយ្យ
២. យល់ដឹងបន្ថែមអំពីកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ
៣. ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមអំពីវិស័យគណនេយ្យនៅកម្ពុជា

កម្មវិធីនេះត្រូវបានបញ្ចប់នៅថ្ងៃខែឆ្នាំដដែលប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

---

## វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី “បច្ចុប្បន្នភាពនៃបទប្បញ្ញត្តិគណនេយ្យនៅកម្ពុជា”



នារសៀលថ្ងៃព្រហស្បតិ៍ ១០ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា គ.ស.២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី “**បច្ចុប្បន្នភាពនៃបទប្បញ្ញត្តិគណនេយ្យនៅកម្ពុជា**” ក្រោមអធិបតីភាព លោកស្រី **សាវុធ ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.** អមដោយលោក **ជា ឆួន** នាយកផ្នែកអប់រំនៃ **វ.គ.ស.ក.** និងលោក **សឿន បូតេ** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាពនៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាវាគ្មិនផងដែរ នៅសណ្ឋាគារភ្នំពេញ។ វគ្គបណ្ដុះបណ្ដាលនេះមានការអញ្ជើញចូលរួមពីសាស្ត្រាចារ្យចំនួន៣៧រូបមកពី១៩គ្រឹះស្ថានឧត្តមសិក្សា។ ជាលទ្ធផល វគ្គបណ្ដុះបណ្ដាលនេះចូលរួមក្នុងការពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូបន្ថែមដូចជា÷

- ចំណេះដឹងទាក់ទងនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម
- ការវិវត្តនៃបទប្បញ្ញត្តិគណនេយ្យនិងសវនកម្មនៅកម្ពុជា
- ការបង្រៀនមុខវិជ្ជាគណនេយ្យឱ្យកាន់តែមានប្រសិទ្ធភាព។

កម្មវិធីនេះត្រូវបានបញ្ចប់នៅម៉ោង៤:៤០នាទីរសៀល ប្រកបដោយផ្លែផ្កា និងភាពរីករាយក្រៃលែង។

## សិក្ខាសាលាអនឡាញស្តីពី “ការណែនាំជំហានឆ្ពោះទៅរកការអនុវត្តប្រព័ន្ធគណនេយ្យប្រកបដោយជោគជ័យ”



នាព្រឹកថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា គ.ស.២០២៤ ចាប់ពីម៉ោង ៩:០០ ដល់ ១១:២៤ព្រឹក វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និងនិយ័តករគណនេយ្យ និងសវនកម្ម (**ន.គ.ស.**) បានសហការរៀបចំសិក្ខាសាលាអនឡាញ ស្តីពី “**សមាជិកភាពរបស់ វ.គ.ស.ក. និងការស្នើសុំអាជ្ញាបណ្ណពី ន.គ.ស.**” ដោយមានការចូលរួមធ្វើបទបង្ហាញពីវាគ្មិនកិត្តិយស កញ្ញា **គីង កែវពិសី** មន្រ្តីជាន់ខ្ពស់ផ្នែកចុះឈ្មោះ និងសមាជិកភាព នៃ **វ.គ.ស.ក.** និងលោក **ស៊ុន ស៊ីម** ប្រធានការិយាល័យអាជ្ញាបណ្ណ នៃ **ន.គ.ស.**។ សិក្ខាសាលាអនឡាញនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងណែនាំអំពីសមាជិកភាពរបស់ **វ.គ.ស.ក.** ជាពិសេសការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងការស្នើរសុំអាជ្ញាបណ្ណពី **ន.គ.ស.**។ សិក្ខាសាលាអនឡាញនេះត្រូវបានធ្វើឡើងដោយជោគជ័យ និងទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកចូលរួមសរុបចំនួន ២៧៥ នាក់។

---

## សិក្ខាសាលាមួយរយៈពេល ២ថ្ងៃស្តីពី “សៀវភៅណែនាំការអនុវត្តសវនកម្ម (APM)”



វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(**វ.គ.ស.ក.**) បានរៀបចំសិក្ខាសាលាមួយរយៈពេល ២ថ្ងៃស្តីពី “**សៀវភៅណែនាំការអនុវត្តសវនកម្ម** (APM)” នៅថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ ទី ២៦ និង ២៧ ខែកញ្ញា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៨:៣០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច នៅសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) សម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន ៤៩នាក់មកពីសមាជិក **វ.គ.ស.ក.** សមាជិកក្រុមហ៊ុន **វ.គ.ស.ក.** និងទស្សនិកជនទូទៅ។

---

## សិក្ខាសាលាអនឡាញស្តីពី “ការណែនាំជំហានឆ្ពោះទៅរកការអនុវត្តប្រព័ន្ធគណនេយ្យប្រកបដោយជោគជ័យ”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានរៀបចំសិក្ខាសាលាមួយក្រោមប្រធានបទ “**ការណែនាំជំហានឆ្ពោះទៅរកការអនុវត្តប្រព័ន្ធគណនេយ្យប្រកបដោយជោគជ័យ**”ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៧ ខែតុលា ឆ្នាំ ២០២៤ ចាប់ពីម៉ោង ៩:00 នាទីព្រឹក ដល់ ម៉ោង ១១: ៣០ នាទីព្រឹក។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត(CPD) សម្រាប់សមាជិក **វ.គ.ស.ក.** និងការលូតលាស់នៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន២៥០នាក់។

## សិក្ខាសាលាស្តីពី “CIFRS 15”



វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយមានកិច្ចសហការពីក្រុមហ៊ុន PKF Covenant Co., Ltd. បានរៀបចំសិក្ខាសាលាស្តីពី “CIFRS 15” នៅថ្ងៃព្រហស្បតិ៍ ទី 24 ខែតុលា ឆ្នាំ 2024 ចាប់ពីម៉ោង 9:00 ព្រឹក ដល់ 5:00 ល្ងាច នៅសណ្ឋាគារភ្នំពេញ។

សិក្ខាសាលានេះគឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) សម្រាប់សមាជិក **វ.គ.ស.ក.** និងឧស្សាហកម្មគណនេយ្យដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យដោយទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកចូលរួមចំនួន ៣៦នាក់ ដែលជាសមាជិក **វ.គ.ស.ក.** គណនេយ្យករ សវនករ ក្រុមហិរញ្ញវត្ថុ អ្នកគ្រប់គ្រងជាន់ខ្ពស់ និងផ្នែកពាក់ព័ន្ធផ្សេងទៀត។

---

## សិក្ខាសាលាអនឡាញស្តីពី “នីតិវិធីនៃការបើក និងបិទក្រុមហ៊ុន”




នាព្រឹកថ្ងៃពុធ ១៣ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែតុលា គ.ស.២០២៤ វេលាម៉ោង ៩:០០ ដល់ ១០:៣៥ ព្រឹក ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំសិក្ខាសាលាអនឡាញស្តីពី “**នីតិវិធីនៃការបើក និងបិទក្រុមហ៊ុន**” ដោយមានការចូលរួមផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ជាវាគ្មិនដោយ **ឯកឧត្តម មួន សារៈមុន្នី** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម និងធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងអំពីនីតិវិធីនៃការបើក និងបិទក្រុមហ៊ុនដល់ធុរជន និងវិនិយោគិន។ ជាលទ្ធផលសិក្ខាសាលានេះទទួលបានជោគជ័យ និងមានអ្នកចូលរួមសរុបចំនួន ៨២០ នាក់។

---

## វគ្គណែនាំសមាជិកដំបូង ( Membership Induction Course)



នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៤ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានរៀបចំវគ្គណែនាំសមាជិកដំបូង ( Membership Induction Course) របស់ខ្លួនសម្រាប់សមាជិកថ្មី ឆ្នាំ២០២៤ សរុប ៥៥ រូប នៅសណ្ឋាគារហ៊ីម៉ារ៉ាវី។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងការយល់ដឹងបន្ថែមអំពីវិទ្យាស្ថាន សមាជិកភាពនិងកាតព្វកិច្ច គោលការណ៍នៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត(CPD) កម្មវិធីបច្ចេកទេសគណនេយ្យ(ATQ) ជូនដល់សមាជិករបស់ខ្លួន និងជាពិសេសការអបអរសាទរដល់សមាជិកថ្មីផងដែរ។ លទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះ សមាជិកថ្មីដែលបានចូលរួមទាំងអស់មានមោទនភាពដែលបានចូលរួមជាសមាជិករបស់ **វ.គ.ស.ក.** និងប្តេជ្ញាចូលរួមអភិវឌ្ឍខ្លួនឯងបន្ថែមជាប្រចាំជាមួយវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំដោយ **វ.គ.ស.ក.** ។ កម្មវិធីនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា ភាពរីករាយ និងចំណងទាក់ទងរវាងគ្នានឹងគ្នាកាន់តែរឹងមាំ។

សិក្ខាសាលាអនឡាញស្តីពី “បច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ”



នៅថ្ងៃសុក្រ ៥ កើត ខែកត្តិក ឆ្នាំរោង ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា គ.ស. ២០២៤ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ ១១:៥០ ព្រឹក វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) បានសហការជាមួយ អគ្គនាយកដ្ឋានពន្ធដារ(**អ.ព.ដ.**) រៀបចំសិក្ខាសាលាអនឡាញដែលជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត ស្តីពី “**បច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ**” ដោយមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយសតំណាងពីអគ្គនាយកដ្ឋានពន្ធដារ លោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បីធ្វើបទបង្ហាញពីបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដើម្បីឱ្យអ្នកជាប់ពន្ធអនុវត្តបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។ សិក្ខាសាលានេះត្រូវបានធ្វើឡើងដោយជោគជ័យ ដោយទទួលបានការចាប់អារម្មណ៍ពីអ្នកចូលរួមចំនួន ១០០០ នាក់។

---

សិក្ខាសាលាអនឡាញស្តីពី “សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ”



នៅព្រឹកថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរោង ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា គ.ស. ២០២៤ ចាប់ពីម៉ោង ៩:០០ នាទីព្រឹក ដល់ ១១:០០ នាទីព្រឹក វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានសហការជាមួយ អគ្គនាយកដ្ឋានពន្ធដារ (**អ.ព.ដ.**) រៀបចំសិក្ខាសាលាអនឡាញដែលជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តស្តីពី “**សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ**” ដោយមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយសតំណាងពីអគ្គនាយកដ្ឋានពន្ធដារ លោកស្រី **អ៊ុក ម៉ូលីតា** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បី÷

១. បង្ហាញឱ្យអ្នកជាប់ពន្ធ សាធារណជន ទាំងអស់បានយល់អំពីទិដ្ឋភាពទាំងស្រុងនៃមុខងារសវនកម្មពន្ធដារ ប្រភេទសវនកម្មពន្ធដារ

២. បែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារតាមប្រភេទសវនកម្មពន្ធដារនីមួយៗ និងបែបបទនិងនីតិវិធីនៃការតវ៉ា សិទ្ធិ អំណាច និង

៣. កាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ និងអ្នកជាប់ពន្ធ ក្រមសីលធម៌វិន័យ និងវិជ្ជាជីវៈ យន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ និងយន្តការរាយការណ៍ និងប្តឹង។

សិក្ខាសាលានេះត្រូវបានធ្វើឡើងដោយជោគជ័យ និងទទួលបានការចាប់អារម្មណ៍ពីអ្នកចូលរួមសរុបចំនួន ៦០៥ នាក់។

### សិក្ខាសាលាអនឡាញស្ដីពី “ការផ្ទេរថ្លៃ”



នៅព្រឹកថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំរោង ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា គ.ស. ២០២៤ ចាប់ពីម៉ោង ៩:០០ នាទីព្រឹក ដល់ ១១:០០ នាទីព្រឹក វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) បានសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ (**អ.ព.ដ.**) រៀបចំសិក្ខាសាលាអនឡាញដែលជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្តស្ដីពី “**ការផ្ទេរថ្លៃ**” ដោយមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយសតំណាងពីអគ្គនាយកដ្ឋានពន្ធដារ លោក **ទ្រី ច័ន្ទតារារិទ្ធ** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ។

សិក្ខាសាលានេះ មានគោលបំណងបង្ហាញដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ដូចជា៖

១. បានសិក្សាស្វែងយល់អំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្ទេរថ្លៃ
២. ទិដ្ឋភាពទូទៅ សារៈសំខាន់ស្ដីពីការផ្ទេរថ្លៃ
៣. កត្តាកំណត់ភាពដែលអាចធៀបបាន វិធីសាស្ត្រផ្ទេរថ្លៃ និងការកាន់កាប់រក្សាទុកឯកសារ។

សិក្ខាសាលានេះត្រូវបានធ្វើឡើងប្រកបដោយភាពជោគជ័យ និងទទួលបានការចាប់អារម្មណ៍ពីអ្នកចូលរួមសរុបចំនួន ៥៥៧ នាក់។

## អនុស្សរណៈនៃការយោគយល់គ្នា

### ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និង សាលា អ៊ីផឡូ ប៊ីស្សនេស



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង សាលា អ៊ីផឡូ ប៊ីស្សនេស ស្ដីពីការទទួលយកកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យទៅបង្រៀន និងការទទួលស្គាល់សាលា អ៊ីផឡូ ប៊ីស្សនេស ជាស្ថាប័នបណ្តុះបណ្តាលដៃគូ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០ នាទីព្រឹក នៅបន្ទប់ប្រជុំ **វ.គ.ស.ក.**។

កិច្ចសហការនេះគឺជាជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបង្កើនឱកាសសម្រាប់សិស្សានុសិស្សនៅក្នុងកម្មវិធីបច្ចេកទេសគណនេយ្យ (ATQ) ។ តាមរយៈនៃការចុះអនុស្សរណៈនេះ យើងនឹងធ្វើការសម្របសម្រួលកម្មសិក្សា ដែលផ្ដល់នូវបទពិសោធក្នុងពិភពពិតដ៏មានតម្លៃ និងកំណើនវិជ្ជាជីវៈគណនេយ្យករមួយដ៏ពិតប្រាកដ។

---

### ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និង សាលា ឡា ប៉េ ប៊ីហ្សនេស



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង សាលា ឡា ប៉េ ប៊ីហ្សនេស ស្ដីពីការទទួលយកកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យទៅបង្រៀន និងការទទួលស្គាល់សាលា ឡា ប៉េ ប៊ីហ្សនេស ជាស្ថាប័នបណ្តុះបណ្តាលដៃគូដែលប្រព្រឹត្តទៅនៅថ្ងៃទី ៩ ខែកញ្ញា គ.ស.២០២៤ វេលាម៉ោង ៣:១៥ នាទីរសៀល នៅបន្ទប់ប្រជុំ **វ.គ.ស.ក.**។

កិច្ចសហការនេះគឺជាជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបង្កើនសុខដុមនីយកម្មនៃកម្មវិធីសិក្សាគណនេយ្យ និងដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់សិស្សានុសិស្សក្នុងការត្រៀមខ្លួនក្លាយជាអ្នកបច្ចេកទេសគណនេយ្យដ៏ពិតប្រាកដ។

### ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច



នាព្រឹកថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា គ.ស.២០២៤ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ស្តីពីការទទួលយកកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យទៅបង្រៀន និងការទទួលស្គាល់សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាស្ថាប័នបណ្តុះបណ្តាលដៃគូបានប្រព្រឹត្តទៅនៅម៉ោង ១០:០០ នាទីព្រឹក នៅសាលប្រជុំ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

កិច្ចសហការនេះគឺជាជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបង្កើនសុខដុមរមនីយកម្មនៃកម្មវិធីសិក្សាគណនេយ្យ និងដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់សិស្សានុសិស្សក្នុងការត្រៀមខ្លួនក្លាយជាអ្នកបច្ចេកទេសគណនេយ្យដ៏ពិតប្រាកដ។

### ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និង ក្រុមហ៊ុន ភី អេ ធី ប្រីហ្វេសិនណល លីមីធីត



នារសៀលថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែតុលា គ.ស.២០២៤ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) និង ក្រុមហ៊ុន ភី អេ ធី ប្រីហ្វេសិនណល លីមីធីត បានប្រព្រឹត្តទៅនៅម៉ោង ២:០០ នាទីរសៀលនៅបន្ទប់ប្រជុំ វ.គ.ស.ក.។ អនុស្សរណៈនេះមានគោលបំណងផ្តល់ឱកាសជូននិស្សិតដែលកំពុងសិក្សាកម្មវិធីបច្ចេកទេសគណនេយ្យ (ATQ) ចុះកម្មសិក្សាផ្ទាល់ជាមួយក្រុមហ៊ុន ភី អេ ធី ប្រីហ្វេសិនណល លីមីធីត ដែលជាសមាជិកសកម្ម របស់ **វ.គ.ស.ក.** ក្នុងការផ្តល់សេវាកម្មគណនេយ្យ និងសវនកម្ម។ បន្ថែមលើខ្លឹមសារនេះក្រុមហ៊ុន ភី អេ ធី ប្រីហ្វេសិនណល លីមីធីត នឹងជំរុញលើកទឹកចិត្តឱ្យបុគ្គលិករបស់ខ្លួនចូលរួមសិក្សា និងប្រឡងក្នុងកម្មវិធីបច្ចេកទេសគណនេយ្យផងដែរ។

កិច្ចសហការនេះគឺជាជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់សិស្សានុសិស្សក្នុងការត្រៀមខ្លួនក្លាយជាអ្នកបច្ចេកទេសគណនេយ្យដ៏ពិតប្រាកដ។

### ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង វ.គ.ស.ក. និង សាកលវិទ្យាល័យមេគង្គកម្ពុជា



នាព្រឹកថ្ងៃសុក្រ ៩កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែតុលា គ.ស.២០២៤ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(**វ.គ.ស.ក.**) និង សាកលវិទ្យាល័យមេគង្គកម្ពុជាស្តីពីការទទួលយកកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យទៅបង្រៀន និងការទទួលស្គាល់សាកលវិទ្យាល័យមេគង្គកម្ពុជាជាស្ថាប័នបណ្តុះបណ្តាលដៃគូបានប្រព្រឹត្តទៅនៅម៉ោង ១០:០០ នាទីព្រឹក នៅសាលប្រជុំនៃសាកលវិទ្យាល័យមេគង្គកម្ពុជា។

កិច្ចសហការនេះគឺជាជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបង្កើនសុខដុមនីយកម្មនៃកម្មវិធីសិក្សាគណនេយ្យ និងដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់សិស្សានុសិស្សក្នុងការត្រៀមខ្លួនក្លាយជាអ្នកបច្ចេកទេសគណនេយ្យដ៏ពិតប្រាកដ។

# កិច្ចសហការនិងការចូលរួមជាមួយស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិនានា

**វ.គ.ស.ក.** បានចូលរួមក្នុងសកម្មភាពនានា ជាមួយស្ថាប័នជាតិ និងអន្តរជាតិដូចជា៖

| | |
|---|---|
| | **និយ័តករគណនេយ្យនិងសវនកម្ម** |
| ១ | សម្របសម្រួលដល់សមាជិករបស់ **វ.គ.ស.ក.** ចូលរួមស្ទង់មតិតាមអនឡាញដើម្បីបញ្ជាក់ពីចំណាប់អារម្មណ៍ និងមតិយោបល់ក្នុងការចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) និងចុះឈ្មោះជាគណនេយ្យករជំនាញបរទេស (RFPA) តាមការស្នើសុំ នៅថ្ងៃទី១២ ខែមករា |
| ២ | រៀបចំតារាងសង្ខេបទិន្នន័យបច្ចុប្បន្នភាពសមាជិករបស់ **វ.គ.ស.ក.** ជាជនជាតិខ្មែរដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្លាយជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) តាមការស្នើសុំ |
| ៣ | រៀបចំរបាយការណ៍ត្រីមាសនៃឆ្នាំ២០២៤ របស់ **វ.គ.ស.ក.** ជូនដល់ **ន.គ.ស.** |
| ៤ | រៀបចំព័ត៌មានលើផ្នែកដែលពាក់ព័ន្ធនឹង **វ.គ.ស.ក.** នៅក្នុងព្រឹត្តិបត្រព័ត៌មានប្រចាំ២០២៣ របស់និយ័តករគណនេយ្យនិងសវនកម្ម តាមការស្នើសុំ |
| ៥ | រៀបចំតារាងសង្ខេបទិន្នន័យពាក់ព័ន្ធនឹងសូចនាករហានិភ័យសំខាន់ៗ (KRIs) សម្រាប់ការអនុវត្តគម្រោងរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដំណាក់កាលទី១ តាមការស្នើសុំ |
| ៦ | ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈដែលរៀបចំដោយ **ន.គ.ស.** លើ “**សេចក្តីព្រាង អនុក្រឹត្យ ស្តីពី ការពិន័យអន្តរការណ៍ចំពោះបទល្មើស នឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម**” នៅថ្ងៃទី១៨ ខែមីនា |
| ៧ | ចូលរួមកិច្ចប្រជុំលើកទី៩ របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា នៅថ្ងៃទី១៩ ខែមីនា តាមរយៈប្រព័ន្ធអនឡាញ |
| ៨ | ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើ “**សេចក្តីព្រាងប្រកាសស្តីពីការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យ**” នៅថ្ងៃទី២៥ ខែមីនា |
| ៩ | សម្របសម្រួលចែកចាយគំរូស្ទង់មតិតាមប្រព័ន្ធអនឡាញ ជូនដល់គណនេយ្យករដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន តាមរយៈសារអេឡិចត្រូនិច នៅថ្ងៃទី២៧ ខែមីនា |
| ១០ | សម្របសម្រួល និងរៀបចំលិខិតលើសំណើសុំការស្រាយបំភ្លឺជាថ្មីម្តងទៀតពី **ន.គ.ស.** លើខ្លឹមសារមួយចំនួនដែលមាននៅក្នុងប្រកាស ស្តីពី “**ការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម**” ជូនដល់សមាជិក **វ.គ.ស.ក.** |
| ១១ | ចូលរួមកិច្ចប្រជុំបន្តលើ “**សេចក្តីព្រាងប្រកាស ស្តីពី ការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង**” នៅថ្ងៃទី២៦ ខែមេសា តាមប្រព័ន្ធអនឡាញ |
| ១២ | ចូលរួម និងធ្វើបទបង្ហាញស្តីពី “**សមាជិកភាពរបស់ វ.គ.ស.ក.**” ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី “**ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ គណនេយ្យនិងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ**” នៅថ្ងៃទី២៩ ខែមេសា នៅសណ្ឋាគារភ្នំពេញ |
| ១៣ | ចូលរួម កិច្ចប្រជុំបន្តលើ “**សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង**” នៅថ្ងៃទី៣ ខែឧសភា តាមប្រព័ន្ធអនឡាញ |
| ១៤ | ចូលរួម កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី “**ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញ** (ISA for LCEs)” នៅថ្ងៃទី១០ ខែឧសភា |

| | |
|---|---|
| ១៥ | ចូលរួម កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើ "**សេចក្ដីព្រាងប្រកាសស្ដីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង**" នៅថ្ងៃទី២០ ខែឧសភា |
| ១៦ | រៀបចំលិខិតតាមរយៈ **ន.គ.ស.** ដើម្បីគោរពជូនជ្រាបជាព័ត៌មានដល់ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ស្ដីពី ការរៀបចំកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំលើកទី២១ របស់ **វ.គ.ស.ក.** |
| ១៧ | អញ្ជើញតំណាង **ន.គ.ស.** ចំនួន ១រូប ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធ គណនេយ្យករអាស៊ាន AFA (ASEAN Federation of Accountants) លើកទី១៣៨ នៅប្រទេសម៉ាឡេស៊ី |
| ១៨ | ស្នើសុំចាត់តំណាង **ន.គ.ស.** ១ (មួយ)រូបដើម្បីចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** អាណត្តិទី៧ (ឆ្នាំ២០២៤-២០២៨) និងទទួលបានការឆ្លើយតបរួចរាល់ |
| ១៩ | អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១០របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា នៅថ្ងៃទី១១ ខែកក្កដា |
| ២០ | សង្ខេបនូវទិន្នន័យប្រចាំឆមាសទី១ ស្ដីពី បច្ចុប្បន្នភាពសមាជិករបស់ **វ.គ.ស.ក.** ជាជនជាតិខ្មែរដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ក្លាយជាគណនេយ្យករជំនាញអាស៊ាន (ASEAN CPA) ជូនដល់ **ន.គ.ស.** កាលពីថ្ងៃទី១២ ខែកក្កដា |
| ២១ | ចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "**លទ្ធផលនៃការចុះត្រួតពិនិត្យគុណភាពសវនកម្មសម្រាប់ឆ្នាំ២០២៣ និងទិសដៅការងារបន្តលើកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្ម**" កាលពីថ្ងៃទី២៥ ខែកក្កដា នៅអាគារ៣៤៥ បានឆ្លើយតបលើសំណើពិនិត្យ និងផ្ដល់យោបល់លើការអនុវត្តស្តង់ដា ISA for LCE ដោយរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពី "**ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញនៅកម្ពុជា** (ISA for LCE)" កាលពីថ្ងៃទី២២ ខែសីហា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី |
| ២២ | ស្នើសុំនិងសហការរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី "**បច្ចុប្បន្នភាពនៃបទប្បញ្ញត្តិគណនេយ្យនៅកម្ពុជា**" កាលពីថ្ងៃទី១២ ខែសីហា នៅសណ្ឋាគារភ្នំពេញ |
| ២៣ | រៀបចំជូននូវ របាយការណ៍ស្ដីពី ការស្ទាប់ស្ទង់មតិក្នុងការទទួលយកនិងការអនុវត្តស្តង់ដា ISA for LCE ជូនដល់ **ន.គ.ស.** នៅថ្ងៃទី២៦ ខែសីហា |
| ២៤ | ចាត់បញ្ជូនតំណាង ៧ (ប្រាំពីរ)រូប ចូលរួមជាសមាជិកគណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់វិស័យឯកជន (**គ.ប.អ.ស.**) កាលពីថ្ងៃទី២៨ ខែសីហា ដែលក្នុងនោះរួមមាន÷<br>- តំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ចំនួន៣រូប<br>១. លោក **ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.**<br>២. លោក **នៅ រ៉េមី** អនុប្រធានក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.**<br>៣. លោកស្រី **សាខុន ដាលី** នាយកប្រតិបត្តិនៃ **វ.គ.ស.ក.**<br>- តំណាងក្រុមហ៊ុនគណនេយ្យ និង/ ឬ សវនកម្ម ជាសមាជិកសកម្ម របស់ **វ.គ.ស.ក.** ចំនួន៤រូប<br>៤. លោក **ជូ ជាមាស** ប្រធានសវនករជាន់ខ្ពស់ តំណាងក្រុមហ៊ុន ឌីឡូយត៍ (ខេមបូឌា) ខូ អិលធីឌី<br>៥. លោក **ង៉ែ ហ៊ុយ** ប្រធាននាយកដ្ឋានសវនកម្ម តំណាងក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា<br>៦. លោកស្រី **ឡុន ស៊ីនរតនា** នាយកក្រុមហ៊ុន តំណាងក្រុមហ៊ុន អឺនស្ទ័ អ៊ែន យ៉ាំង (ខេមបូឌា)<br>៧. លោកស្រី **មាធុរស្ស ផាត ម៉ូលីហង្សណា** នាយក (Partner) តំណាងក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស (ខេមបូឌា) |
| ២៥ | ស្នើសុំ និងសហការរៀបចំកម្មវិធីសិក្ខាសាលាអនឡាញស្ដីពី "**សមាជិកភាពរបស់ វ.គ.ស.ក. និងការស្នើសុំអាជ្ញាបណ្ណពី ន.គ.ស.**" កាលពីថ្ងៃទី១៩ ខែកញ្ញា តាមរយៈប្រព័ន្ធអនឡាញ |

| | |
|---|---|
| ២៦ | ស្នើសុំ និងទទួលនូវសៀវភៅណែនាំអំពីការអនុវត្តការងារសវនកម្ម- Audit Practice Manual សម្រាប់ជាឯកសារចាំបាច់ក្នុងកម្មវិធីសិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពី "**Audit Practice Manual (APM)**" តាមការស្នើសុំ កាលពីថ្ងៃទី១៦ ខែកញ្ញា និងបានទទួលឯកសារគ្រប់ចំនួនរួចរាល់ |
| ២៧ | សហការរៀបចំកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពី "**ស្តង់ដារសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញនៅកម្ពុជា** (ISA for LCE)" កាលពីថ្ងៃទី២៧ ខែកញ្ញានៅសណ្ឋាគារហ៊ីម៉ាវ៉ារី |
| ២៨ | ទទួលនូវ ប្រកាសលេខ ០៥៥ អ.ស.ហ.ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា គ.ស. ២០២៤ ស្ដីពី ប្រកាសការតែងតាំងប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧របស់ **វ.គ.ស.ក.** កាលពីថ្ងៃទី១៦ ខែកញ្ញា និងបន្តបញ្ជូនប្រកាសជូនដល់សមាជិកពាក់ព័ន្ធជ្រាបជាព័ត៌មាន និងរបាយការណ៍ |
| ២៩ | បញ្ជូនឈ្មោះមន្ត្រីជំនាញរបស់ **វ.គ.ស.ក.** ចំនួន២ (ពីរ)រូប ដើម្បីចូលរួមការចុះត្រួតពិនិត្យគុណភាពលើក្រុមហ៊ុនសវនកម្មដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្មដោយស្របច្បាប់នៅកម្ពុជា គឺកញ្ញា **គីង កែវពិសី** មន្ត្រីជាន់ខ្ពស់ផ្នែកចុះឈ្មោះ និងសមាជិកភាពនៃ **វ.គ.ស.ក.** និងលោក **ម៉ូច សុវណ្ណរតនៈ** មន្ត្រីផ្នែកសមាជិកភាព នៃ **វ.គ.ស.ក.** |
| ៣០ | ចូលរួម កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ លើថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ថ្ងៃទី១៦ ខែកញ្ញា |
| ៣១ | ចូលរួមជាដៃគូរសហការឧបត្ថម្ភ ចំនួន២០០០០ដុល្លារអាមេរិចគត់ តាមការស្នើសុំនៃកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ស្ដីពី "**តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០**" នៅថ្ងៃទី១៧ និង១៨ ខែតុលា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ |
| ៣២ | ចូលរួមជាអ្នកសហការរៀបចំកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ ស្ដីពី "**តួនាទីនៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០**" នៅថ្ងៃទី១៧ និង១៨ ខែតុលា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ |
| ៣៣ | ចូលរួមកិច្ចប្រជុំបើក ស្ដីពី "**ការចុះត្រួតពិនិត្យគុណភាពសវនកម្មលើក្រុមហ៊ុនសវនកម្មសម្រាប់ឆ្នាំ២០២៤**" នៅថ្ងៃទី២២ ខែ តុលា នៅបន្ទប់ប្រជុំ **ន.គ.ស.** |
| ៣៤ | រៀបចំលិខិតស្នើសុំ **ន.គ.ស.** ពិនិត្យ និងផ្ដល់អនុសាសន៍ លើសេចក្ដីព្រាងនៃនីតិវិធីប្រតិបត្តិស្តង់ដា ស្ដីពី ការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មវិន័យ របស់ **វ.គ.ស.ក.** នៅថ្ងៃទី២៤ ខែតុលា |
| ៣៥ | ចូលរួមកិច្ចប្រជុំលើកទី៤១ នៃក្រុមការងារអ្នកជំនាញការអន្តររដ្ឋាភិបាល (The 41st International Standards of Accounting and Reporting-ISAR Meeting) តាមរយៈការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ម៉ី ដារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ស្ដីពី ស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ ដែលបានបង្កើតឡើងដោយ ECOSOC នាឆ្នាំ១៩៨៣ (ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃស្តង់ដាគណនេយ្យនិងការរាយការណ៍អន្តរជាតិ -International Standard of Accounting and Reporting ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤) នៅថ្ងៃទី៦ ដល់ទី៨ ខែវិច្ឆិកា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស |
| ៣៦ | ទទួលនូវការឆ្លើយតបចំពោះការផ្ដល់យោបល់របស់ **ន.គ.ស.** លើសេចក្ដីព្រាងនៃនីតិវិធីប្រតិបត្តិស្តង់ដា ស្ដីពី ការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មវិន័យ របស់ **វ.គ.ស.ក.** នៅថ្ងៃទី២០ ខែវិច្ឆិកា រួចរាល់ |
| ៣៧ | ទទួលនូវ សេចក្ដីចម្លងជូន ស្ដីពី របាយការណ៍ស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារឆ្នាំ២០២៣ ពី **ន.គ.ស.** នៅថ្ងៃទី២០ ខែវិច្ឆិកា និងរក្សាទុកជាឯកសារផ្ទៃក្នុង |
| ៣៨ | ចូលរួមកិច្ចប្រជុំអនឡាញ ស្ដីពី "**លទ្ធផលនៃការចុះត្រួតពិនិត្យគុណភាពសវនកម្ម លើក្រុមហ៊ុនសវនកម្មសម្រាប់ឆ្នាំ២០២៤**" នៅថ្ងៃទី៣ ខែធ្នូ |

| | |
|---|---|
| ៣៩ | ទទួលជ្រាបជាព័ត៌មាន និងឯកសារ នៅថ្ងៃទី៣ ខែធ្នូ ស្តីពី ចំណារដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ លើ លិខិតលេខ១០៩៨០ សវ/អស៊/កបទ.សអ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** ចំពោះករណីសំណើសុំអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់លើ ការកំណត់មិនអនុញ្ញាតឱ្យមីយ៉ាន់ម៉ា ធ្វើជា អនុប្រធានសហប្រធាន ឬប្រធាន នៃកិច្ចប្រជុំតាមវិស័យ និងមិនអនុញ្ញាតឱ្យមីយ៉ាន់ម៉ារៀបចំ កិច្ចប្រជុំតាមវិស័យនៅប្រទេសរបស់ខ្លួន |
| ៤០ | ទទួលជ្រាបជាព័ត៌មាន និងឯកសារ នៅថ្ងៃទី៥ ខែធ្នូ ចំពោះ ប្រកាសលេខ ០៦៧ អ.ស.ហ.ប្រ.ក. ចុះថ្ងៃទី២១ ខែវិច្ឆិកា គ.ស.២០២៤ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការបច្ចេកទេសគាំទ្រការអនុវត្តស្តង់ដាគណនេយ្យស្តង់ដាសវនកម្ម និងការអះអាងនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស័យឯកជន |
| ៤១ | ចូលរួមកិច្ចប្រជុំក្រុមការងារ ដើម្បីពិនិត្យ និងពិភាក្សាលើប្រធានបទក្នុងការរៀបចំកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ នៅថ្ងៃទី២៤ ខែធ្នូ នៅបន្ទប់ប្រជុំ ន.គ.ស. |

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | |
|---|---|
| ១ | ទទួលជ្រាបជាព័ត៌មាន នៅថ្ងៃទី២៦ ខែធ្នូ ចំពោះលិខិតលេខ ១៣៧០១ សហវ.ល.ស. ចុះថ្ងៃទី២៤ ខែធ្នូ គ.ស.២០២៤ ស្តីពី ការស្នើសុំចាត់តំណាង ៣(បី)រូប ចូលរួមជាសមាជិកគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យ សម្រាប់វិស័យសាធារណៈ(**គ.ស.ស.**) និងបានកំពុងបន្តធ្វើការងារផ្ទៃក្នុង ដើម្បីឆ្លើយតប និងជម្រាបជូនដល់ **ឯកឧត្តមបណ្ឌិត ទី តាយី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

## ក្រសួងពាណិជ្ជកម្ម

| | |
|---|---|
| ១ | ស្នើសុំកិច្ចសហប្រតិបត្តិការចាត់តំណាងចូលរួមជាវាគ្មិនជំនាញក្នុងកម្មវិធីសិក្ខាសាលាអនឡាញ ស្តីពី “**នីតិវិធីនៃការបើក និងបិទក្រុមហ៊ុន**” និងទទួលបានការឆ្លើយតបរួចរាល់ |
| ២ | សហការរៀបចំកម្មវិធីសិក្ខាសាលាអនឡាញ ដែលមានការចូលរួមជាវាគ្មិនកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយ **ឯកឧត្តម ប្វូន សារៈមុនី** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ក្រោមប្រធានបទ “**នីតិវិធីនៃការបើក និងបិទក្រុមហ៊ុន**” នៅថ្ងៃទី៣០ ខែតុលា ដោយជោគជ័យ |

## អគ្គនាយកដ្ឋានពន្ធដារ

| | |
|---|---|
| ១ | ចែករំលែកព័ត៌មានដល់សមាជិកតាមរយៈសារអេឡិចត្រូនិច ស្តីពី កំណត់ហេតុអង្គប្រជុំកិច្ចប្រជុំពិភាក្សាលើបញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារជាមួយសភាពាណិជ្ជកម្មកម្ពុជា និងក្រុមការងារផ្នែកនីតិកម្មពន្ធដារនិងអភិបាលកិច្ច រវាងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន នៅថ្ងៃទី២២ ខែកុម្ភៈ |
| ២ | ចែករំលែកព័ត៌មានដល់សមាជិកតាមរយៈសារអេឡិចត្រូនិច ស្តីពី កំណត់ហេតុអង្គប្រជុំកិច្ចប្រជុំពិភាក្សាលើ បញ្ហាប្រឈមពាក់ព័ន្ធនឹងពន្ធដារក្នុងក្របខណ្ឌក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន នៅថ្ងៃទី២២ ខែកុម្ភៈ |
| ៣ | ស្នើសុំកិច្ចសហប្រតិបត្តិការ ចាត់តំណាងចូលរួមជាវាគ្មិនជំនាញ ក្នុងកម្មវិធីសិក្ខាសាលាអនឡាញក្រោមប្រធានបទចំនួនបីគឺ (១)បច្ចុប្បន្នភាពពន្ធដារ (២)ការផ្ទេរថ្លៃ (Transfer Pricing) និង (៣) ការធ្វើសវនកម្មពន្ធដារ និងទទួលបានការឆ្លើយតបរួចរាល់ |

| | |
|---|---|
| ៤ | សហការរៀបចំកម្មវិធីសិក្ខាសាលាអនឡាញ ចំនួន៣ ដោយជោគជ័យក្នុងនោះ÷<br>១. នៅថ្ងៃទី៨ ខែវិច្ឆិកា ក្រោមប្រធានបទ “**បច្ចុប្បន្នភាពពន្ធដារ**”<br>២. នៅថ្ងៃទី១២ ខែវិច្ឆិកា ក្រោមប្រធានបទ “**សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ**” និង<br>៣. នៅថ្ងៃទី១៩ ខែវិច្ឆិកា ក្រោមប្រធានបទ “**ការផ្ទេរថ្លៃ**” |

## ធនាគារជាតិនៃកម្ពុជា

| | |
|---|---|
| ១ | ស្នើសុំចាត់តំណាង **ធ.ជ.ក.** ១ (មួយ)រូប ដើម្បីចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** អាណត្តិទី៧ (ឆ្នាំ២០២៤-២០២៨) និងទទួលបានការឆ្លើយតបរួចរាល់ |
| ២ | សុំកិច្ចសហប្រតិបត្តិការ ចាត់តំណាងចូលរួមជាវាគ្មិនជំនាញ ក្នុងកម្មវិធីសិក្ខាសាលាអនឡាញ ស្តីពី “**ការផ្លាស់ប្តូររូបិយបណ្ណបរទេសមកជាប្រាក់រៀលក្នុងប្រព័ន្ធគណនេយ្យ** (Converting Foreign Currency to KHR in Accounting System)” |

## International Federation of Accountants (IFAC)

| | |
|---|---|
| ១ | រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (ATQ) ជាមួយកញ្ញា Tanya Musumhi តំណាងរបស់ IFAC នៅថ្ងៃទី២៩ ខែមករា តាមប្រព័ន្ធអនឡាញ |
| ២ | រៀបចំកិច្ចប្រជុំពិភាក្សា ជាមួយនាយកផ្នែកអប់រំរបស់ IFAC ចំនួន២ដង តាមប្រព័ន្ធអនឡាញ |
| ៣ | ប្រជុំពិភាក្សាជាមួយកញ្ញា Tanya Musumhi តំណាងរបស់ IFAC នៅថ្ងៃទី១៣ ខែមីនា និងថ្ងៃទី២៦ ខែមីនា តាមប្រព័ន្ធអនឡាញ |
| ៤ | ចូលរួមកិច្ចប្រជុំ IFAC Asia-Pacific Sustainability Exchange នៅថ្ងៃទី២៥ ខែមេសា តាមប្រព័ន្ធអនឡាញ |
| ៥ | រៀបចំកិច្ចប្រជុំផ្ទាល់រវាង **វ.គ.ស.ក. ន.គ.ស.** ជាមួយកញ្ញា Tanya Musumhi តំណាងសហព័ន្ធគណនេយ្យករអន្តរជាតិ-International Federation of Accountants (IFAC) ស្តីពីការធ្វើបច្ចុប្បន្នភាព **វ.គ.ស.ក.** ក្នុងការស្នើសុំជាសមាជិកពេញសិទ្ធរបស់ IFAC និងកិច្ចពិភាក្សាលម្អិតទៅលើលក្ខខណ្ឌបន្ថែមដែល **វ.គ.ស.ក.** ត្រូវអនុវត្តជូនដល់ IFAC នៅថ្ងៃទី២៩ ខែមេសា នៅបន្ទប់ប្រជុំ **វ.គ.ស.ក.** |
| ៦ | ពិនិត្យ និងបំពេញកម្រងសំណួររបស់ IFAC (Membership Engagement Questionaries) |
| ៧ | ចូលរួមកិច្ចប្រជុំពិភាក្សាអនឡាញ រវាង **វ.គ.ស.ក. ន.គ.ស.** ACCA និង IFAC ស្តីពី ការធ្វើបច្ចុប្បន្នភាពនិងលក្ខខណ្ឌផ្សេងទៀតដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់ IFAC និងចំណុចពាក់ព័ន្ធទៅនឹង ACCA Sponsorship ចំនួន៥ដង |
| ៨ | ចូលរួមកិច្ចប្រជុំពិភាក្សាអនឡាញជាមួយនាយកអប់រំផ្នែកគណនេយ្យ IFAC នៅថ្ងៃទី៥ ខែវិច្ឆិកា |
| ៩ | ចូលរួមសិក្ខាសាលាអនឡាញថ្នាក់តំបន់របស់ IFAC និង AFA ស្តីពី Developing an Effective PAO Strategy នៅថ្ងៃទី១៤ ខែវិច្ឆិកា |

## ACCA Cambodia

| | |
|---|---|
| ១ | ចូលរួមកិច្ចប្រជុំពិភាក្សាអំពីវឌ្ឍនភាពវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ក៏ដូចជាលទ្ធភាពនៃកិច្ចសហប្រតិបត្តិការជាមួយ **វ.គ.ស.ក.** នាពេលខាងមុខជាមួយ លោក Airil Razali, CEO នៃ TYMBA ដែលជាស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈមួយនៃប្រទេសម៉ាឡេស៊ី និងក្រុមការងារ ដែលសម្របសម្រួល និងដឹកនាំដោយលោក **នួច រតនា**, Head of ACCA Cambodia នៅថ្ងៃទី១៨ ខែមករា |
| ២ | សហការ បំពេញព័ត៌មានផ្សេងៗ និងបញ្ជូនឯកសារពាក់ព័ន្ធនឹងបច្ចុប្បន្នភាព ដើម្បីក្លាយជាសមាជិកពេញសិទ្ធ IFAC របស់ **វ.គ.ស.ក.** ដល់ ACCA ដើម្បីពិនិត្យ និងផ្តល់យោបល់បន្ថែមជាពិសេសការរៀបចំសេចក្តីព្រាងស្តីពី នីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មវិន័យរបស់ **វ.គ.ស.ក.** |
| ៣ | ចូលរួមកិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **វ.គ.ស.ក.** និង ACCA លើកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរក្នុងនោះវត្តមានរបស់លោក Aucky Pratama ប្រធានផ្នែកសាធារណៈ ACCA ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ដើម្បីទស្សនកិច្ច **វ.គ.ស.ក.** ក្រោមការសម្របសម្រួលដោយលោក **នួច រតនា**, Head of ACCA Cambodia នៅថ្ងៃទី១៤ ខែតុលា និង |
| ៤ | ចូលរួមកម្មវិធីសិក្ខាសាលាចែករំលែកចំណេះដឹង និងកម្មវិធីចុះអនុស្សរណៈនៃការយោគយល់រវាង អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងអេស៊ីស៊ីអេ (ACCA Global) នៅថ្ងៃទី៩ ខែធ្នូ នៅទីស្តីការ **អ.ស.ហ.** |

## ASEAN Federation of Accountants (AFA)

| | |
|---|---|
| ១ | ចូលរួមកិច្ចប្រជុំពិភាក្សាលើ AFA Office Bearers និង AFA Secretariat នៅថ្ងៃទី២០ ខែមីនា តាមរយៈប្រព័ន្ធអនឡាញ |
| ២ | ចូលរួមក្នុង កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន -AFA (ASEAN Federation of Accountants) លើកទី១៣៨ នៅសណ្ឋាគារ Mandarin Oriental នាប្រទេសម៉ាឡេស៊ី នៅថ្ងៃទី១៣ ខែមិថុនា |
| ៣ | ស្នើសុំទៅនាយកប្រតិបត្តិនៃសហព័ន្ធគណនេយ្យករអាស៊ាន (AFA) ឱ្យជួយសម្របសម្រួលក្នុងការរៀបចំ កិច្ចពិភាក្សា ការចែករំលែកបទពិសោធន៍ល្អៗក្នុងការរៀបចំយន្តការ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មវិន័យនៃវិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យសិង្ហបុរី ម៉ាឡេស៊ីនិងឥណ្ឌូណេស៊ី |
| ៤ | ចូលរួមកិច្ចប្រជុំអនឡាញ ដើម្បីពិភាក្សាលើកិច្ចការងារត្រូវរៀបចំនាពេលខាងមុខ ស្តីពី កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន -AFA (ASEAN Federation of Accountants) លើកទី១៤០ និងសន្និសីទថ្នាក់តំបន់ (AFA & KICPAA Conference) ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ នៅថ្ងៃទី១១ ខែវិច្ឆិកា |
| ៥ | ចូលរួមសិក្ខាសាលាអនឡាញ (AFA - ACCA Webinar) ស្តីពី Implementation of IFAC Statement of Membership Obligations 6 Investigation & Discipline (SMO 6 I&D) នៅថ្ងៃទី២៨ ខែវិច្ឆិកា |
| ៦ | ចូលរួមកម្មវិធីសន្និសីទថ្នាក់តំបន់របស់ AFA និង PICPA (AFA & PICPA Conference) នៅថ្ងៃទី២២ ខែវិច្ឆិកា នៅ SMX Convention Center ទីក្រុង Davao ប្រទេសហ្វីលីពីន |
| ៧ | ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន -AFA (ASEAN Federation of Accountants) លើកទី១៣៩ នៅសណ្ឋាគារ Acacia Hotel Davao នាប្រទេសហ្វីលីពីន នៅថ្ងៃទី២៣ ខែវិច្ឆិកា។ ក្នុងនោះក៏មានការប្រកាសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំក្រុម ប្រឹក្សាភិបាលនៃសហព័ន្ធគណនេយ្យករអាស៊ាន លើកទី១៤០ និងសន្និសីទថ្នាក់តំបន់នៅក្នុងខែឧសភា ឆ្នាំ២០២៥ ដែលរៀបចំដោយ **វ.គ.ស.ក.** |

## និយ័តករមូលបត្រកម្ពុជា

| | |
|---|---|
| ១ | ចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធលើសេចក្តីព្រាងប្រកាសស្តីពី “**ការបង្ហាញព័ត៌មាននិរន្តរភាព**” នៅថ្ងៃទី១៩ ខែមករា |
| ២ | ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ លើសេចក្តីព្រាងប្រកាសស្តីពី “**ការបង្ហាញព័ត៌មានចីរភាព**” នៅថ្ងៃទី២ ខែកុម្ភៈ |
| ៣ | ស្នើសុំចាត់តំណាង **ន.ម.ក.** ១ (មួយ)រូប ដើម្បីចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** អាណត្តិទី៧ (ឆ្នាំ២០២៤-២០២៨) និងទទួលបានការឆ្លើយតបរួចរាល់ |

## និយ័តករធានារ៉ាប់រងកម្ពុជា

| | |
|---|---|
| ១ | ជួយសម្របសម្រួលក្នុងការអញ្ជើញតំណាងរបស់ក្រុមហ៊ុនសវនកម្មចូលរួម វគ្គបណ្តុះបណ្តាល ស្តីពីបច្ចុប្បន្នភាពកម្រៃសេវាសាធារណៈដែលប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមករា |
